# គិហិសេដ្ឋោ

## ធម៌នមស្ការ សមាទានសីល ពាក្យវេរផ្សេងៗ
## បកិណ្ណកវិន័យដែលគ្រហស្ថគួរយល់ដឹង

ការផ្សាយរបស់វត្តគីរីសុវណ្ណភូមិ អំពាយស្វាយ

ព.ស.២៥៦៧ គ.ស.២០២៣

(សម្រាប់ជាធម្មទាន)

# គិហិសេដ្ឋោ

## “គ្រហស្ថដ៏ប្រសើរ”

### ធម៌នមស្ការ  សមាទានសីល ពាក្យវេរផ្សេងៗ

### បកិណ្ណវិន័យដែលគ្រហស្ថគួរយល់ដឹង

ការផ្សាយរបស់វត្តគិរីសុវណ្ណភូមិ“អំពាយស្វាយ”

ព.ស.២៥៦៧  គ.ស.២០២៣

(សម្រាប់ជាធម្មទាន)

សៀវភៅឈ្មោះ **គិហិសេដ្ឋោ “គ្រហស្ថដ៏ប្រសើរថ្លៃថ្លា”**

ផ្តួចផ្តើមគំនិត លោកម្ចាស់គ្រូ វីរិយបញ្ញោ **ចៅ វុត្ថា** ព្រះគ្រូ
ចៅអធិការ វត្តគិរីសុវណ្ណភូមិ

ប្រមូលរៀបរៀង ព្រះមហា សន្តិបាលោ**ចៅ ភេន**
សាមណេរ និសភោ **ចៅ វណ្ណា**

អ្នកវាយអត្ថបទ សាមណេរ ធម្មឱសថោ **លូ រ៉ាំងហូ**
សាមណេរ និសភោ **ចៅ វណ្ណា**

ពិនិត្យដោយ ព្រះមហា រតនសុភោ **សូ សារុន** ធម្មាចារ្យ
ព្រះភិក្ខុ សមាធិរតោ **ចៅ វ៉ាង**
ព្រះភិក្ខុ ចន្ទនកប្បោ **ទៀង បុង**
ព្រះភិក្ខុ វិមលោ **សាន ថាវីន** វិនិយាចារ្យ

ទីកន្លែងធ្វើ វត្តគិរីសុវណ្ណភូមិ “អំពាយស្វាយ”
ភូមិអំពាយស្វាយ ឃុំអាងគី ស្រុកទិនបៀង
ខេត្តអាងយ៉ាង ( កម្ពុជាក្រោម )

កាលបរិច្ឆេទ ព.ស. ២៥៦៧ គ.ស. ២០២៣

# អារម្ភកថា

សៀវភៅឈ្មោះ គិហិសេដ្ឋោ នេះ ខ្ញុំព្រះករុណា បានសិក្សាមកក្នុងព្រះពុទ្ធសាសនា ក៏មានសទ្ធាជ្រះថ្លា បានដកស្រង់ចេញពីគម្ពីរនានា ធ្វើជាកូនសៀវភៅតូចមួយសម្រាប់ធម្មទានដើម្បីតម្កល់ទុកក្នុងព្រះពុទ្ធសាសនា និងដើម្បីជាមត៌ក ដល់សាសនិកជនជំនាន់ក្រោយ និងដើម្បីបានជាប្រយោជន៍ដល់ពុទ្ធបរិស័ទ ដែលជាអ្នកប្រាថ្នាចង់ចេះដឹង យកមកប្រតិបត្តិតាមព្រះពុទ្ធវចន ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសសម្តែងហើយ ឱ្យត្រឹមត្រូវក្នុងការប្រព្រឹត្តប្រចាំថ្ងៃ ។ អាស្រ័យហេតុដូច្នេះហើយ ទើបខ្ញុំព្រះករុណាបានបោះពុម្ពសៀវភៅនេះឡើងជាធម្មទាន ដល់ពុទ្ធបរិស័ទទាំងឡាយ ។

ធម្មតាការសរសេរសៀវភៅនេះឡើង ពិតណាស់គង់តែមានការខ្វះខាត ត្រង់ចំណុចណាមួយជាក់ជាពុំខាន សូមអ្នកសិក្សាមេត្តាជួយកែតម្រូវ នូវរាល់ចំណុចដែលខ្វះទាំងនោះ ដើម្បីឱ្យបានត្រឹមត្រូវតាមលំអាននៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។

ដោយអំណាចបុណ្យ ដែលកើតពីធម្មទាននេះ សូមលើកឡើងឧទ្ទិសដល់ ក្រុមជំនុំព្រះត្រៃបិដក បុព្វបុរសខ្មែរដែលបានពលីជីវិតក្នុងការរក្សាការពារមាតុភូមិ និងអ្នកមានឧបការៈក្នុងការកសាង**វត្តគិរីសុវណ្ណភូមិ** (អំពាយស្វាយ) ព្រមទាំងសូមឧទ្ទិសដល់ពពួកញាតិទាំងឡាយ ទេវតាទាំងឡាយ សូមបានអនុមោទនា ទទួលយកនូវចំណែកបុណ្យរបស់ខ្ញុំផងចុះ ។

មួយវិញទៀត សូមប្រគេន និងជូននូវបុណ្យកុសលដល់ ព្រះសង្ឃគ្រប់ព្រះអង្គ និងញាតិញោមពុទ្ធបរិស័ទគ្រប់គ្នា ដែលបានចូលរួមបោះពុម្ពសៀវភៅនេះ ឬបានអានសៀវភៅនេះ សូមឱ្យបាននូវសេចក្តីសុខ រួចផុតចាកសេចក្តីទុក្ខទាំងពួង ។

ថ្ងៃ១០ កើត ខែ ជេស្ឋ ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី ២៩ ខែ ឧសភា គ.ស. ២០២៣

**គណសង្ឃវត្តគិរីសុវណ្ណភូមិ“អំពាយស្វាយ”**

# មាតិកាធម៌

អារម្ភកថា.................................................................................. ១
បទសារភញ្ញ ............................................................................... ១
រតនបណាមវិធី ............................................................................២
គាថាសរសើរគុណព្រះសម្មាសម្ពុទ្ធ .........................................១៣
រតនត្តយបូជា (ការបូជារតនត្រ័យ)........................................ ១៦
ពុទ្ធរតនប្បណាម (ថ្វាយបង្គំព្រះពុទ្ធ)....................................១៧
ធម្មរតនប្បណាម (ថ្វាយបង្គំព្រះធម៌)....................................២០
សង្ឃរតនប្បណាម (ថ្វាយបង្គំព្រះសង្ឃ) ................................ ២៣
សរសើរគុណ និង ថ្វាយបង្គំព្រះរតនត្រ័យ...............................២៧
នមស្សការដោយអធិដ្ឋាន ........................................................២៩
នមស្សការបូជនីយវត្ថុជាទីគោរព...........................................៣០
នមស្សការពុទ្ធបាទ...................................................................៣១
បត្តិទានគាថា.............................................................................. ៣៣
យំកិញ្ចិ ប្រែពាក្យកាព្យ ..............................................................៣៥
បុព្វភាគប្បដិបត្តិ (កិច្ចបដិបត្តិខាងដើម) ................................. ៣៧
ឧបាសកនិទ្ទេស ........................................................................ ៤៦

សីលនៃឧបាសក ........................................................ ៤៨

វិធីសមាទាននិច្ចសីល ........................................................ ៤៨

វិធីសមាទានឧបោសថសីល ........................................................ ៥៥

អង្គនៃសិក្ខាបទ ក្នុងនិច្ចសីល........................................................ ៦៥

អង្គនៃសិក្ខាបទ ក្នុងឧបោសថសីល ........................................................៦៧

កុសលកម្មបថ១០(កម្មដែលជាផ្លូវនាំទៅសុគតិ)........................................................ ៦៩

អកុសលកម្មបថ១០(កម្មដែលជាផ្លូវនាំទៅអបាយភូមិ)........................................................៧១

អង្គនៃអកុសលកម្មបទ........................................................៧២

បរិត្តភាសនាយាចនគាថា ........................................................៧៦

ធម្មគារវៈ ការគោរពព្រះធម៌........................................................៧៦

កំណាព្យសរសើគុណព្រះធម៌ ........................................................៧៨

អង្គរបស់អ្នកសូធ្យ និងអ្នកស្តាប់ ព្រះបរិត្ត........................................................៧៩

អាជីវៈនៃឧបាសក ឧបាសិកា........................................................ ៨០

វិបត្តិនៃឧបាសក ឧបាសិកា ........................................................ ៨១

សម្បត្តិនៃឧបាសក ឧបាសិកា........................................................៨៣

គុណសម្បត្តិរបស់ឧបាសក ឧបាសិកា ........................................................ ៨៤

សាច់ជាអកប្បិយៈមិនគួរប្រគេន........................................................៨៧

សាច់បរិសុទ្ធ ៣ យ៉ាង........................................................ ៨៨

ការប្រគេនព្រះសង្ឃដែលត្រឹមត្រូវ ..................................... ៨៩
ការដាច់ប្រគេន មានដោយហេតុ ៧យ៉ាង គឺ ..................................... ៩៣
ការធ្វើកប្បិយៈ (ធ្វើរបស់មិនគួរ ឲ្យគួរបរិភោគបាន) ..................... ៩៧
សមណកប្បៈ ៥ យ៉ាង ..................................................................... ៩៧
**ពាក្យវេរផ្សេង ៗ** ..................................................................... ១០០
១.ពាក្យវេរបិណ្ឌបាតថ្វាយព្រះសម្មាសម្ពុទ្ធ ..................................... ១០០
២.ពាក្យវេរផ្កាថ្វាយចំពោះព្រះរតនត្រ័យ ..................................... ១០១
៣.ពាក្យវេរថ្វាយកឋិនចំពោះសង្ឃ ..................................... ១០៣
៤.ពាក្យវេរសេនាសនៈថ្វាយសង្ឃ ..................................... ១០៤
៥.ពាក្យវេរគម្ពីរព្រះត្រៃបិដក និងអដ្ឋកថា ..................................... ១០៥
៦.ពាក្យវេរសង្ឃភត្តថ្វាយសង្ឃ ..................................... ១០៦
៧.ពាក្យវេរសង្ឃភត្តថ្វាយចំពោះសង្ឃ ..................................... ១០៧
វិធីអបលោកន៍ ..................................................................... ១១១
ការបវារណា (និមន្តឲ្យប្រើប្រាស់) ..................................... ១១៤
របៀបបវារណាបច្ច័យ ៤ ..................................................................... ១១៥
ពាក្យបវារណាអកប្បិយវត្ថុ ..................................................................... ១១៦
ការនិមន្តព្រះសង្ឃគង់ចាំវស្សា ..................................................................... ១១៨
អនុមោទនារក្ខាយាចនគាថា ..................................................................... ១១៩

តេជះខ្ញុំសាង........................................................................... ១២១
ពាក្យឧទ្ទិទានសសង្ខេប................................................................. ១២១
ពាក្យឧទ្ទិទានមួយបែបទៀត.........................................................១២២
សព្វទិសាសុមេត្តាផរណំ...............................................................១២៣
ផ្សាយមេត្តាចិត្តដល់សព្វសត្វសង្ខេប ........................................... ១២៦
មួយបែបទៀតថា ...........................................................................១២៧
ពាក្យអធិដ្ឋានទាន.........................................................................១២៧
ពាក្យអធិដ្ឋាន............................................................................... ១២៨

# បទសារភញ្ញ

សូមថ្វាយបង្គំព្រះសម្ពុទ្ធ　　ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្សនិងទេវតា　　ទ្រង់ត្រាស់ទេសនាប្រដៅសត្វ ។
ចង្អុលឱ្យដើរផ្លូវកណ្ដាល　　មាគ៌ាត្រកាលអាចកំចាត់
ទុក្ខភ័យចង្រៃឱ្យខ្ចាយបាត់　　អាចកាត់សង្សារទុក្ខបាន ។
សាសនាព្រះអង្គនៅសព្វថ្ងៃ　　សត្វមាននិស្ស័យពីបុរាណ
ប្រឹងរៀនប្រឹងស្ដាប់ចេះចាំបាន　　កាន់តាមលំអានបានក្ដីសុខ ។
ឥតមានសុខណាស្មើក្ដីស្ងប់　　បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះតទៅមុខ　　ក្ដីសុខនឹងមានព្រោះធម៌ស្ងប់ ។
ខ្ញុំសូមបង្គំឆ្ពោះព្រះធម៌　　ព្រះសង្ឃបវរទាំងគ្រប់សព្វ
រួមជាត្រៃរ័ត្នគួរគោរព　　ជាម្លប់ត្រជាក់នៃលោកា ។
ព្រះរូបព្រះធាតុនៃព្រះពុទ្ធ　　វិសុទ្ធតាងអង្គព្រះសាស្ដា
សូមគុណត្រៃរ័ត្នជួយខេមរា　　ឱ្យបានសុខាតរៀងទៅ ។

# វន្ទនបណាមវិធី

## (វិធីនៃការថ្វាយបង្គំព្រះរតនត្រ័យ)

## សេចក្តីពន្យល់

**បណាម ឬ ប្រណាម** មានន័យ ការបង្អោន ឬការបង្អោនកាយ វាចា ចិត្ត គោរព (ការថ្វាយបង្គំ)។

ការថ្វាយបង្គំនេះមាន ៣ យ៉ាង ដូចមានព្រះបាលី ក្នុងព្រះសុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត (លេខ៤១ ទំព័រ ៤៧៥) ថា៖

**តិស្សោ ឥមា ភិក្ខវេ វន្ទនា ។ កតមា តិស្សោ ។ កាយេន វាចាយ មនសា វន្ទនា ។ ឥមា ខោ ភិក្ខវេ តិស្សោ វន្ទនាតិ ។** ម្នាលភិក្ខុទាំងឡាយ ការថ្វាយបង្គំនេះមាន ៣ យ៉ាង ។ ការថ្វាយបង្គំ ៣ យ៉ាង ដូចម្តេចខ្លះ ។ គឺការ ថ្វាយបង្គំដោយកាយ ១ ដោយវាចា ១ ដោយចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ការ ថ្វាយបង្គំមាន ៣ យ៉ាងនេះឯង។

ក្នុងគម្ពីរបរមត្ថទីបនី ដីកាអភិធម្មត្ថសង្គហៈ លោកពន្យល់ថា៖

**តត្ថ សេដ្ឋចិត្តំ បច្ចុបដ្ឋាបេត្វា ជាណុទ្វយកប្បរទ្វយនលាដសង្ខាតានិ បញ្ច អង្គានិ ភូមិយំ បតិដ្ឋាបេត្វា វន្ទនេយ្យានំ ភិមុខំ និប្បជ្ជន្តោ កាយេន វន្ទតិ នាម ។** បណ្តាការថ្វាយបង្គំទាំង ៣ នោះ

បុគ្គលអ្នកញុំាងចិត្តដ៏ប្រសើរឱ្យតាំងចំពោះមុខ ហើយញុំាងអវយវៈទាំង ៥ គឺជង្គង់២, ដៃ២, ក្បាល១, ឱ្យតាំងនៅលើផ្ទៃរាប លុតជង្គង់ទាំង២ ដាក់ដៃទាំង២ លើផ្ទៃរាប ឱនក្បាលចុះលើផ្ទៃរាបរួមជា៥ ហៅថា ថ្វាយបង្គំដោយបញ្ចង្គ ឬដោយបញ្ចង្គប្រតិស្ឋ ហើយក្រាបចុះចំពោះ មុខបុគ្គលដែលគួរដល់ការថ្វាយបង្គំ ឈ្មោះថា ថ្វាយបង្គំដោយកាយ។

**គុណបទានិ វាចាយ បរិត្តេន្តោ វាចាយ វន្ទតិ នាម ។ “នមោ ពុទ្ធស្ស, នមត្ថុ ពុទ្ធស្ស, នមោ វិមុត្តានំ, នមោ វិមុត្តិយា, វិបស្សិស្ស នមត្ថូ”តិ ឯវមាទីសុបិ វាចា វន្ទនាយេវ ។**

អ្នកពោលស្វាធ្យាយនូវពាក្យដែលសម្តែងសរសើរអំពីគុណ សម្បត្តិ ដោយវាចា ឈ្មោះថា ថ្វាយបង្គំដោយវាចា ។ ដូចជាថ្វាយបង្គំ ដោយពោលថា “**នមោ ពុទ្ធស្ស** ខ្ញុំសូមថ្វាយបង្គំចំពោះព្រះពុទ្ធជាម្ចាស់, **នមត្ថុ ពុទ្ធស្ស** កិរិយាថ្វាយបង្គំនៃខ្ញុំចូរមានចំពោះព្រះពុទ្ធ, **នមោ វិមុត្តានំ** សូមថ្វាយបង្គំចំពោះ( ព្រះពុទ្ធទាំងឡាយ) ដែលទ្រង់រួចផុតហើយ, **នមោ វិមុត្តិយា** សូមថ្វាយបង្គំចំពោះវិមុត្តិធម៌ ( នៃព្រះពុទ្ធទាំងឡាយ នោះ ), **វិបស្សិស្ស នមត្ថុ** សូមថ្វាយបង្គំចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាម វិបស្សី” ដូច្នេះជាដើម ឈ្មោះថា ថ្វាយបង្គំដោយវាចា ។

**គុណបទានិ អនុគន្ធាគុណោ អនុស្សរន្តោ មនសា វន្ទតិ នាម ។** ចំណែកអ្នករឭកដល់គុណសម្បត្តិជារឿយ ៗ ដោយធ្វើតាមពាក្យសម្ដែងគុណសម្បត្តិនោះ ឈ្មោះថា ថ្វាយបង្គំដោយចិត្ត។

ក្នុងគម្ពីរសារត្ថទីបនី ដីកាព្រះវិន័យ លោកសម្ដែងថា៖

**មង្គលភាវតោ សព្វកិរិយាសុ បុព្វកិច្ចភាវតោ បណ្ឌិតេហិ សមាចរិតភាវតោ អាយតឹ បរេសំ ទិដ្ឋានុគតិអាបជ្ជនតោ ច រតនត្តយបណាមកិរិយា ។**

កិរិយានមស្ការថ្វាយបង្គំព្រះរតនត្រ័យ ជាមង្គលផង ជាខាងដើមនៃការងារគ្រប់យ៉ាងផង ជាទំនៀមដែលបណ្ឌិតទាំងឡាយធ្លាប់ប្រព្រឹត្តមកដោយល្អផង និងជាគំរូដល់ពួកជនដទៃក្នុងកាលជាខាងក្រោយផង ។

## អានិសង្សនៃការថ្វាយបង្គំព្រះរតនត្រ័យ

ការនមស្ការថ្វាយបង្គំរំឭកដល់គុណព្រះរតនត្រ័យ គឺជាកិច្ចដ៏សំខាន់មួយរបស់ពុទ្ធសាសនិកជន ព្រោះជាការសម្ដែងនូវសេចក្ដីគោរពក្នុងសរណវត្ថុរបស់ខ្លួន, ដូច្នេះពុទ្ធសាសនិកជនមិនគួរស្ងៀម ឬស្វាធ្យាយនមស្ការចំពោះតែក្នុងពេលមានកម្មវិធីបុណ្យប៉ុណ្ណោះទេ តែគួរនមស្ការរំឭកឱ្យបានគ្រប់ពេលវេលា ឬឱ្យជាប្រចាំតាមដែលអាចធ្វើ

ទៅបាន ព្រោះថា បុគ្គលណាដែលបានធ្វើការគោរពបូជាដល់បុគ្គលដែលគួរបូជា រមែងបាននូវបុណ្យដ៏ច្រើន។

ដូចមានគាថា ដែលបូរាណាចារ្យពោលទុកថា៖

**បុញ្ញវុឌ្ឍិ បាបហានិ រតនត្តយវន្ទនា**

**សាបិ ទេតិ ឥដ្ឋបាកំន ច ទេតិ អនិដ្ឋកំ ។**

កិរិយានមស្ការថ្វាយបង្គំព្រះរតនត្រ័យ ជាគុណជាតិចម្រើនឡើងនៃបុណ្យជាគុណជាតិសូន្យទៅនៃបាប តែងតែឱ្យផលជាទីប្រាថ្នា គឺមិនមែនឱ្យផលដែលមិនជាទីប្រាថ្នាឡើយ ។

នៅក្នុងគម្ពីរអបទាន និងធម្មបទជាដើម មានសម្ដែងអំពីអានិសង្សនៃបុគ្គលអ្នកគោរពបូជា នមស្ការថ្វាយបង្គំចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃថា ក្រោយអំពីស្លាប់ទៅក៏បានទៅកើតជាទេវតា សោយនូវសម្បត្តិជាទិព្វក្នុងទេវលោក លុះអស់ជីវិតអំពីទេវលោក មកកើតជាមនុស្សក្នុងត្រកូលក្សត្រ ឬសេដ្ឋីមហាសាលជាដើម ។

នៅក្នុងព្រះធម្មបទ ត្រង់សហស្សវគ្គ ព្រះដ៏មានព្រះភាគទ្រង់ សម្ដែងនូវព្រះគាថាប្រារព្ធនឹងព្រាហ្មណ៍ជាសំឡាញ់របស់ព្រះសារីបុត្រ អំពីអានិសង្សនៃការថ្វាយបង្គំដូច្នេះថា:

**យង្កិញ្ចិ យិដ្ឋំ វ ហុតំ វ លោកេ សំវច្ឆរំ យជេថ បុញ្ញបេក្ខោ**

**សព្វំបិ តំ ន ចតុភាគមេតិ អភិវាទនា ឧជុគតេសុ សេយ្យោ**

បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជាធំតូចណាមួយក្នុងលោកអស់មួយឆ្នាំ ការបូជាទាំងអស់នោះឯង រមែងមិនដល់នូវចំណែកទី ៤ នៃការអភិវាទន៍ចំពោះលោកទាំងឡាយដែលប្រព្រឹត្តត្រង់ហើយ ការអភិវាទន៍នេះប្រសើរជាង។

ម្យ៉ាងទៀត មិនមែនឱ្យសម្រេចបុណ្យកុសលតែក្នុងអនាគតកាលប៉ុណ្ណោះ ទេ ថែមទាំងអាចជួយការពារនូវអន្តរាយច្រើនយ៉ាងមិនឱ្យកើតមានដោយអំណាច នៃឧបត្ថម្ភកកម្មចូលទៅជួយឧបត្ថម្ភដល់ជនកកម្ម ។

សួរថាៈ ការថ្វាយបង្គំព្រះរតនត្រ័យ អាចកម្ចាត់ឧបសគ្គបានយ៉ាងណា ?

ឆ្លើយថាៈ ការថ្វាយបង្គំព្រះរតនត្រ័យ ជាក្រសែបុណ្យដ៏ធំដែលញ៉ាំងកិរិយានមស្ការថ្វាយបង្គំ ឱ្យសម្រេចប្រព្រឹត្តទៅគ្រប់ៗជវនចិត្ត ៧ខណៈរហូតច្រើនសែនកោដិខណៈ ។

ក្រសែបុណ្យនោះ ជាបុណ្យធំទូលាយ មានអានុភាពច្រើនមានផលច្រើនព្រោះចម្រើនក្នុងស្រែបុណ្យដ៏ប្រសើរ មានព្រះពុទ្ធជាដើម និងបានអប់រំទុកដោយគុណ គឺឆន្ទៈ សទ្ធា និងបញ្ញាដ៏ធំមហា

សាល ។ បុណ្យដ៏ធំធេងនោះ តាំងនៅក្នុងការដល់ព្រមដោយសេចក្ដីព្យាយាម កម្ចាត់ហេតុវិបត្តិខាងក្រៅជាហេតុឱ្យបានទទួលសម្បត្តិធ្វើសេចក្ដីចម្រើនដល់ធាតុទាំង ៤ ដែលស្ថិតនៅក្នុងរាងកាយ ដែលកើតអំពីឧតុ ចិត្តនិងអាហារដ៏ប្រណីតឧបត្ថម្ភដល់ជនកកម្មដែលបានទទួលឱកាសតាំងអំពីបដិសន្ធិកាល ទាំងបើកឱកាសដល់កុសលដទៃដែលនៅមិនទាន់មានឱកាសឱ្យផល ។

លំដាប់នោះ ក្រសែរូបធម៌ នាមធម៌ដែលកើតអំពីបុណ្យទាំង ២ ដែលបានទទួលកម្លាំងឧបត្ថម្ភ និងបានឱកាសហុចផលឱ្យមានកម្លាំងខ្លាំងបន្តដំណើរជីវិតឱ្យប្រព្រឹត្តទៅដូចស្ទឹងធំ ២ ខ្សែក្នុងក្រសែចិត្តធ្វើឱ្យឧបសគ្គ គឺរោគជាដើមដែលជាផលមិនល្អ មិនមានឱកាសកើតក្នុងក្រសែចិត្តដែលពេញព្រៀបដោយផលល្អដូច្នោះ អកុសលកម្មដែលនឹងទម្លាយផលល្អ និងបង្កឱ្យកើតផលមិនល្អ ទើបត្រូវកម្ចាត់ទៅព្រោះកុសលកម្ម និងអកុសលកម្មរមែងមិនហុចផលឱ្យ កាលបើមិនមានឱកាសនឹងឱ្យផលទេនោះ ។ ដោយហេតុនោះ ធម៌ដែលជាផលល្អមានអាយុ និងវណ្ណៈជាដើម ទើបតាំងនៅក្នុងផ្នែកចម្រើនក្នុងក្រសែចិត្តថែមទាំងតែងគម្ពីរសម្រេច ឬស្វម្បីទីបំផុតនៃអាយុកប្ប ដូចព្រះពុទ្ធវចនៈថា:

**អភិវាទនសីលិស្ស     និច្ចំ វុឌ្ឍាបចាយិនោ**

**ចត្តារោ ធម្មា វឌ្ឍន្តិ     អាយុ វណ្ណោ សុខំ ពលំ ។**

ធម៌៤ប្រការ គឺ អាយុ១ វណ្ណៈ១ សុខៈ១ ពលៈ១ រមែងចម្រើនដល់អ្នកដែលមានសេចក្តីឱនកាយថ្វាយបង្គំជាប្រក្រតី មានសេចក្តីកោតក្រែងដល់បុគ្គលដែលចម្រើនជាងខ្លួន(ដោយគុណ ឬ វ័យ) អស់កាលជានិច្ច ។

ចំណែកនៅក្នុងអដ្ឋកថាធម្មបទ បកិណ្ណកវគ្គ មាននិទានរឿងកុមារសម្មាទិដ្ឋិម្នាក់ជាអ្នកជ្រះថ្លាចំពោះព្រះពុទ្ធគុណ កូននោះតែងបញ្ចេញវាចាថ្វាយបង្គំព្រះពុទ្ធជារឿយ ៗ ថា នមោ ពុទ្ធស្ស។ ខ្ញុំសូមថ្វាយបង្គំព្រះពុទ្ធ ។ ។ សូម្បីពេលវាលេងបោះអង្គញ់ជាមួយពួកក្មេងដទៃ មុននឹងបោះអង្គញ់ទៅ វាតែងតែពោលថានមោ ពុទ្ធស្ស ។ ហើយគាត់លេងឈ្នះគេរាល់លើក ។ ថ្ងៃមួយវាបានជិះរទេះទៅកាប់ឧសក្នុងព្រៃជាមួយនឹងឳពុក លុះវេលាល្ងាចពេលជិតនឹងត្រឡប់មកផ្ទះវិញ គោទាំង ២ ក៏រត់ទៅផ្ទះមុន ឳពុកក៏ទៅតាមចាប់គោមកទឹមរទេះតែកាលចាប់គោបានហើយ មិនអាចនឹងចេញមកបានព្រោះត្រូវគេបិទទ្វារព្រះនគរក៏នៅខាងក្នុងកំពែងនោះទៅ ។ ឯកូននៅចាំរទេះតែម្នាក់ឯង ចេះតែទន្ទេញថា នមោ ពុទ្ធស្ស ។ មិនដាច់ពីមាត់កំពុង

តែទន្ទេញនោះឯងក៏ដេកលក់ទៅ ។ ក្នុងព្រៃនោះមានយក្សពីរនាក់ ១ ជាសម្មាទិដ្ឋិ ១ ជាមិច្ឆាទិដ្ឋិ យក្សទាំងពីរនាក់នោះនាំគ្នាចេញទៅរកចំណីអាហារក្នុងវេលាយប់ ក៏បានឃើញកុមារនោះដេកក្រោមរទេះម្នាក់ឯង យក្សមិច្ឆាទិដ្ឋិប្រុងចាប់ស៊ី តែត្រូវយក្សសម្មាទិដ្ឋិឃាត់ តែយក្សនោះមិនស្តាប់ហើយក៏ចូលទៅចាប់ទាញជើងកុមារ កុមារក៏ស្រែកឡើងថា នមោ ពុទ្ធស្ស ។ យក្សនោះក៏ភ័យញ័ររន្ធត់ ទន់ជើងទន់ដៃស្ទើរស្លាប់រកចាប់ស៊ីក៏ពុំកើត ។ យក្សទាំងពីរក៏នៅចាំរក្សាការពារកុមារនោះអស់មួយយប់ យក្សជាសម្មាទិដ្ឋិបានបង្គាប់យក្សមិច្ឆាទិដ្ឋិឱ្យទៅយកក្រយាស្ងោព្រះរាជាក្រុងរាជគ្រឹះមកឱ្យកុមារបរិភោគ លុះព្រឹកឡើងពួករាជបុរសតាមរកភាជន៍ក្រយាស្ងោយ ក៏ឃើញក្នុងរទេះបាននាំភាជន៍និងកុមារទៅថ្វាយព្រះរាជា ។ កុមារបានទូលរឿងនោះសព្វគ្រប់ ព្រះរាជាក៏ទ្រង់នឹកស្ងើចហើយបាននាំកុមារទៅថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ...។ លំដាប់នោះព្រះរា-ជាក៏ទ្រង់ទូលសួរថា “ បពិត្រព្រះអង្គដ៏ចម្រើន មានតែពុទ្ធានុស្សតិប៉ុណ្ណោះឬ ទើបជាគ្រឿងរក្សាការពារ ឬថាអនុស្សតិដទៃក៏ជាគ្រឿងរក្សាការពារបានដែ ? ” ។ ព្រះសាស្តាត្រាស់តបនឹងព្រះរាជាថា “បពិត្រមហារាជ មិនមែនមានតែពុទ្ធានុស្សតិតែម៉្យាងប៉ុណ្ណោះទេដែលជាគ្រឿងរក្សាការពារនោះ, ក៏

ពួកជនណា បានអប់រំចិត្តល្អហើយក្នុងឋានៈ ៦ យ៉ាង កិច្ចដោយការរក្សា និងការការពារយ៉ាងដទៃ ឬដោយមន្ត និងឱសថ រមែងមិនមានដល់ជនទាំងនោះឡើយ ” ហើយក៏ត្រាស់នូវគាថា ដែលនឹងដកយកតែ ៣ ព្រះគាថា ដូចមានខាងក្រោមនេះ ៖

**សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា**
**យេសំ ទិវា ច រត្តោ ច និច្ចំ ពុទ្ធគតា សតិ ។**

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងព្រះពុទ្ធគុណអស់កាលជានិច្ចទាំងថ្ងៃទាំងយប់ ជនពួកនោះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់ រឭកៗដោយប្រពៃសព្វកាល ។

**សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា**
**យេសំ ទិវា ច រត្តោ ច និច្ចំ ធម្មគតា សតិ ។**

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងព្រះធម្មគុណ អស់កាលជានិច្ចទាំងថ្ងៃទាំងយប់ ជនពួកនោះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់ រឭកៗ ដោយប្រពៃសព្វកាល ។

**សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា**
**យេសំ ទិវា ច រត្តោ ច និច្ចំ សង្ឃគតា សតិ ។**

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងព្រះសង្ឃគុណ អស់កាលជានិច្ចទាំងថ្ងៃ ទាំងយប់ ជនពួកនោះឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់ រឭកៗដោយប្រពៃសព្វកាល ។

ក្នុងធជគ្គសូត្រ បិដកលេខ៣០ ទំព័រ២៤៣ ព្រះមានព្រះភាគទ្រង់ដាស់តឿនដល់ភិក្ខុទាំងឡាយថា បើពួកអ្នកនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តីឬក៏នៅក្នុងផ្ទះស្ងាត់ក្តី កាលបើសេចក្តីខ្លាចក្តី សេចក្តីរន្ធត់ក្តី សេចក្តីព្រឺរោមក្តីកើតឡើងដល់អ្នកទាំងឡាយៗ គប្បីរឭករឿយៗនូវព្រះពុទ្ធថា **ឥតិបិ សោភគវា**..., បើមិនរឭកនូវព្រះពុទ្ធទេ គប្បីរឭកនូវព្រះធម៌ថា **ស្វាក្ខាតោ ភគវតា ធម្មោ**..., បើមិនរឭកនូវព្រះធម៌ទេ គប្បីរំឭកនូវព្រះសង្ឃថា **សុបដិបន្នោ ភគវតោ សាវកសង្ឃោ**...,។ នៅខាងចុងនៃព្រះសូត្រ ព្រះអង្គទ្រង់ត្រាស់នូវព្រះគាថានេះថា

**ឯវំ ពុទ្ធំ សរន្តានំ ធម្មំ សង្ឃញ្ច ភិក្ខវោ**
**ភយំ វា ឆម្ភិតត្តំ វា លោមហំសោ ន ហេស្សតិ ។**

ម្នាលភិក្ខុទាំងឡាយ កាលបើអ្នករាល់គ្នារឭកនូវព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃយ៉ាងនេះ ភ័យក្តី សេចក្តីរន្ធត់ក្តី សេចក្តីព្រឺរោមក្តី នឹងមិនកើតមានឡើយ ។

**រតនប្បណាមវិធី** គឺវិធីនមស្ការថ្វាយបង្គំនូវព្រះរតនត្រ័យនេះ ចែកជា ២បែប គឺបែបពិស្តារ១ យ៉ាង បែបសង្ខេប១ យ៉ាង។ អ្នកដែលមានសេចក្តីជ្រះថ្លាប្រាថ្នានឹងនមស្ការព្រះរតនត្រ័យនោះ ទោះនៅក្នុងទីកន្លែងរបស់ខ្លួន ឬនៅកន្លែងកម្មវិធីបុណ្យណាក៏ដោយ បើមានពេលឱកាសល្មមនឹងសូធ្យនមស្ការ ទាំង ៣ បទឱ្យបានចប់សព្វគ្រប់ដោយសេចក្តីពិស្តារដូចបែបទី ១ ក៏ជាការប្រពៃពេកណាស់ តែបើពេលខ្លីមិនអាចសូធ្យឱ្យចប់សព្វគ្រប់បានទេ ក៏គ្រាន់តែសូធ្យដោយសង្ខេបខ្លីៗ តាមបែបទី ២ ក៏បានដែរ ។

**អប្បមត្តា សតីមន្តោ សុសីលា ហោថ ភិក្ខវោ**

**សុសមាហិតសង្កប្បា សចិត្តមនុរក្ខថ ។**

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរកុំប្រមាទ ត្រូវមានស្មារតី មានសីលល្អ មានតម្រិះតម្កល់នឹងល្អ ចូររក្សាចិត្តរបស់ខ្លួនឲ្យរឿយៗចុះ ។

# គាថាសរសើរគុណព្រះសម្មាសម្ពុទ្ធ

**នមោ តេ បុរិសាជញ្ញ  នមោ តេ បុរិសុត្តម**

**សព្ពញ្ញូសិមហាវីរ  លោកជេដ្ឋ នរាសភ ។**

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាបុរសឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គទ្រង់មានព្យាយាមធំ ជាបុគ្គលខ្ពង់ខ្ពស់ជាងសត្វលោក ប្រសើរជាងនរជន ព្រះអង្គជាព្រះសព្វញ្ញូពុទ្ធ ។  (បិដកលេខ ៧៤/១៩)

**នមោ តេ បុរិសាជញ្ញ  នមោ តេ បុរិសុត្តម**

**ពហុជ្ជនំ តារយសិ  ទេសេន្តោ អមតំ បទំ ។**

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាបុរសឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ ព្រះអង្គកាលទ្រង់សម្តែងនូវអមតបទ គឺព្រះនិព្វាន ញុំាងជនដ៏ច្រើន ឱ្យឆ្លងវដ្តទុក្ខបាន។ (បិដក ៧៣/១៨៨)

**រូបេ សីលេ សមាធិម្ហិ  បញ្ញាយ ច អសាទិសោ**

**វិមុត្តិយាអសមសមោ  ធម្មចក្កប្បវត្តនេ ។**

ព្រះអង្គមិនមានបុគ្គលស្មើក្នុងព្រះរូបផង សីលផង សមាធិផង បញ្ញាផង ព្រះអង្គស្មើដោយព្រះពុទ្ធទាំងឡាយ ដែលមិនមានបុគ្គលស្មើ ចំពោះវិមុត្តិធម៌ និងការញ៉ាំងធម្មចក្កឱ្យប្រព្រឹត្តទៅ ។ (បិដក៧៧/១៣)

**លាភាលាភេ ន សជ្ជន្តិ សម្មានេ វិមាននេ**

**បឋវីសទិសា ពុទ្ធា តស្មា តេ ន វិរោធិយា ។**

ព្រះពុទ្ធទាំងឡាយ មានចិត្តស្មើដោយផែនដី មិនជាប់ជំពាក់ក្នុង លាភ និងអលាភ ក្នុងការរាប់អាន ក្នុងការមើលងាយ ហេតុនោះ បុគ្គលមិនគប្បីឱ្យឆ្គាំឆ្គង នឹងព្រះពុទ្ធទាំងនោះឡើយ។(បិដក៧២/១០៨)

**នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម**

**សទេវកស្មឹ លោកស្មឹ នត្ថិ តេ បដិបុគ្គលោ ។**

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រ ព្រះអង្គជាបុរសឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ ក្នុងលោកនេះព្រមទាំង ទេវលោក មិនមានបុគ្គលណាមួយប្រៀបផ្ទឹមស្មើនឹងព្រះអង្គបានឡើយ ។ (ពុទ្ធប្បវត្តិកថា)

**តុវំ ពុទ្ធោ តុវំ សត្ថា តុវំ មារាភិភូ មុនិ**

**តុវំ អនុសយេ ឆិន្នោ តិណ្ណោ តារេហិ មំ បជំ ។**

ព្រះអង្គជាព្រះពុទ្ធ ព្រះអង្គជាសាស្តាចារ្យ ព្រះអង្គជាអ្នកប្រាជ្ញ ទ្រង់ គ្របសង្កត់នូវពួកមារ ព្រះអង្គជាអ្នកកាត់ផ្តាច់នូវអនុស័យកិលេស ទ្រង់ឆ្លងផុតចាកសង្សារហើយ សូមទ្រង់ចម្លងនូវខ្ញុំព្រះអង្គជាសត្វផង ។ (ពុទ្ធប្បវត្តិកថា)

សូមអនុមោទនា

នូវការពោលសរសើរគុណាព្រះសម្មាសម្ពុទ្ធ !!!

**សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ**

**អសតា ច ន សោចតិ ស វេ ភិក្ខូតិ វុច្ចតិ ។**

ការចាប់ប្រកាន់ក្នុងនាមរូប ថាជារបស់យើងៗ មិនមាន ដល់បុគ្គលណាដោយប្រការទាំងពួង ម្យ៉ាងទៀត បុគ្គលណា មិនសោកសៅព្រោះនាមរូបនោះដែលបាត់ទៅ បុគ្គលនោះឯង តថាគតហៅថា ភិក្ខុ ។

# រតនត្តយបូជា (ការបូជារតនត្រ័យ)

**ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ**
**អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច**
**ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

ខ្ញុំព្រះករុណា សូមបូជាចំពោះ នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀន និងធូបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**
**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**
**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

វីកិរិយានមស្សការថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូលមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ ។

# ពុទ្ធរតនប្បណាម (ថ្វាយបង្គំព្រះពុទ្ធ)

**យោ សន្និសិន្នោ វរពោធិមូលេ**

**មារំ សសេនំ មហតឹ វិជេយ្យោ**

**សម្ពោធិមាគច្ឆិ អនន្តញាណោ**

**លោកុត្តមោ តំ បនមាមិ ពុទ្ធំ ។**

ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើននូវព្រះអានាបានស្សតិកម្មដ្ឋាន លើរតនបល្ល័ង្កក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយគោរព ។

**យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា**

**បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា ។**

ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធ

ទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធ ក្នុងភទ្រកប្បនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង ។

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។**

**ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាពអង្គនោះ ទ្រង់ព្រះនាមថា **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេសព្រមទាំងវាសនាគឺកាយបយោគនិងវចីបយោគ **សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះព្រះអង្គ ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ **វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា **វិជ្ជាចរណសម្បន្នោ** ព្រោះព្រះអង្គបរិបូណ៌ដោយ វិជ្ជា៣និងវិជ្ជា៨ និងចរណ១៥ **សុគតោ** ទ្រង់ព្រះនាមថា **សុគតោ** ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថានគឺអមតមហានិព្វាន **លោកវិទូ** ទ្រង់ព្រះនាមថា **លោកវិទូ** ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក **អនុត្តរោ** ទ្រង់ព្រះនាមថា **អនុត្តរោ** ព្រោះព្រះអង្គប្រសើរ ដោយសីលាទិគុណ រកបុគ្គលណាមួយស្មើ

គ្មាន **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា **បុរិសទម្មសារថិ** ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យ គួរនឹងទូន្មានបាន **សត្ថាទេវមនុស្សានំ** ទ្រង់ព្រះនាមថា **សត្ថាទេវមនុស្សានំ** ព្រោះព្រះអង្គជាសាស្តាចារ្យ នៃទេវតានិងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គ ត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឱ្យត្រាស់ដឹងផង **ភគវា** ទ្រង់ព្រះនាមថា **ភគវា** ព្រោះព្រះអង្គ មានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

**នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ**
**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

**នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹង ទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ **ពុទ្ធោ មេ សរណំ វរំ** មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹង ទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណាដោយកិរិយាពោល នូវពាក្យសច្ចនេះ។

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ**

**ពុទ្ធេ យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ ។**

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវល្អងធូលីព្រះបាទ នៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏ឧត្តមគឺត្បូង **ពុទ្ធេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះពុទ្ធជាម្ចាស់ **ពុទ្ធោ ខមតុ តំ មមំ** សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

# ធម្មរតនប្បណាម (ថ្វាយបង្គំព្រះធម៌)

**អដ្ឋង្គិការិយបថោ ជនានំ**

**មោក្ខប្បវេសាយ ឧជូ ច មគ្គោ**

**ធម្មោ អយំ សន្តិករោ បណីតោ**

**និយ្យានិកោ តំ បនមាមិ ធម្មំ ។**

ព្រះសទ្ធម្មឯណាជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាកន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញ៉ាំងជនដែលប្រាថ្នានូវព្រះនិព្វាន ឱ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះជាធម៌ធ្វើឱ្យត្រជាក់រម្ងាប់បង់ នូវភ្លើងទុក្ខភ្លើងកិលេសជាធម៌ដ៏ឧត្តម ជាគុណញ៉ាំង

សត្វឱ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសទ្ធម្មនោះដោយគោរព ។

**យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា**
**បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ។**

ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ នឹងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះធម៌ទាំងឡាយនោះ គ្រប់កាលទាំងពួង ។

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ**
**ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។**

**ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មាន ព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ ( **ធម្មោ** ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១ ) **សន្ទិដ្ឋិកោ** ជាធម៌គឺ ព្រះអរិយបុគ្គលទាំងពួង ដឹងពិតឃើញពិត ដោយ

បច្ចវេក្ខណញ្ញាណ គឺថានឹងបាន ដឹងដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង **អកាលិកោ** ជាធម៌ឱ្យនូវ ផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផល ក៏កើតក្នុងលំដាប់គ្នាមិនបានយឺតយូរឡើយ **ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គល ដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃ ឱ្យចូលមក មើលបាន **ឱបនយិកោ** ជាធម៌ គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

**នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ**
**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

**នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭកនៃ ខ្ញុំព្រះករុណាមិនមានឡើយ **ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ជាទីពឹង ទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ**

**ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ ។**

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរមានពីរប្រការ គឺព្រះបរិយត្តិធម៌និង ព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តមគឺត្បូង **ធម្មេ យោ ខលិតោ ទោសោ** ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុង ព្រះធម៌ជាម្ចាស់ **ធម្មោ ខមតុ តំ មមំ** សូមព្រះធម៌ជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

# សង្ឃរតនប្បណាម (ថ្វាយបង្គំព្រះសង្ឃ)

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ**
**សន្តិន្ទ្រិយោ សព្វមលប្បហីនោ**
**គុណេហិនេកេហិ សមិទ្ធិបត្តោ**
**អនាសវោ តំ បនមាមិ សង្ឃំ ។**

ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេសជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរម្ងាប់ហើយមានមន្ទិល គឺរាគាទិក្កិលេសទាំងពួង បន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវកិរិយា សម្រេចដោយគុណ

ទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះដោយគោរព ។

**យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា**
**បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា ។**

ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គនិងផលកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គនឹងផលក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ នឹងផលក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសង្ឃទាំងឡាយនោះ គ្រប់កាលទាំងពួង ។

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិ-បដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ-បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ**

**បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។**

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមកន្លងព្រះនព្វលោកុត្តរធម៌ **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រត្តិបត្តិជាមជ្ឈិមបដិបទា **ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹង នូវព្រះនិព្វានជាស្ថានក្សេមផុតចាកទុក្ខទាំងពួង **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា **យទិទំ-ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណាបើរាប់ជាគូនៃបរុសទាំងឡាយមាន ៤ គូគឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ ១ សកទាគាមិមគ្គ និងសកទាគាមិផលជាគូ ១ អនាគាមិមគ្គ និងអនាគាមិផលជាគូ ១ អរហត្តមគ្គ និង អរហត្តផលជាគូ ១ **អដ្ឋបុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺព្រះសង្ឃដែលបានសម្រេច នូវ សោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ

១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ **ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនុះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា **បាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិនិងមិត្ត ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា **ទក្ខិណេយ្យោ** លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្ម ហើយបូជា **អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុសឡើងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

**នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ**
**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

**នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭកនៃ ខ្ញុំព្រះករុណាមិនមានឡើយ **សង្ឃោ មេ សរណំ វរំ** មានតែព្រះសង្ឃជាម្ចាស់ជាទីពឹង ទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ**

សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ**

**សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ ។**

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរមានពីរប្រការ គឺសម្មតិសង្ឃនិងអរិយសង្ឃ ដោយអវយវៈដ៏ឧត្តមគឺត្បូង **សង្ឃេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុង ព្រះសង្ឃជាម្ចាស់ **សង្ឃោ ខមតំ មមំ** សូមព្រះសង្ឃជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា

## សរសើរគុណ និង ថ្វាយបង្គំព្រះរតនត្រ័យ

**យោ កប្បកោដីហិបិ អប្បមេយ្យំ**

**កាលំ ករោន្តោ អតិទុក្ករានិ**

**ខេទំ គតោ លោកហិតាយ នាថោ**

**នមោ មហាការុណិកស្ស តស្ស ។**

ព្រះពុទ្ធជាទីពឹង ជាពំនឹងសព្វសត្តា

ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ ។

រាប់ដោយកោដិកប្បា ច្រើនគណនា ហួសគិតគូរ
បានត្រាស់ជាសព្វញ្ញូ ច្បាស់ជាគ្រូលើភពឋាន ។
ធ្វើកម្មជាកម្រ មនុស្សនិករ ត្រាប់ពុំបាន
តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ ដល់សព្វសត្វ ។
ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នា បង្គំថ្វាត់
ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល។

**អសម្ភុធំ ពុទ្ធនិសេវិតំ យំ**

**ភវាភវំ គច្ឆតិ ជីវលោកោ**

**នមោ អវិជ្ជាទិកិលេសជាលំ**

**វិទ្ធំសិនោ ធម្មវរស្ស តស្ស ។**

សត្វតែងកើតស្លាប់បង់ ព្រោះចំណងកម្មជាគោល
ឱ្យវិលវល់អន្ទោល ក្នុងភពតូចនិងភពធំ ។
ហេតុតែមិនដឹងធម៌ បរិសុទ្ធល្អ ស្អាតសុខុម
គឺព្រះពុទ្ធសេពសម ចិត្តខ្ញុំសូមនមស្សការ ។
នូវធម៌ប្រពៃពិត វិសេសសុទ្ធ នោះឯងណា
កាត់បង់នូវអវិជ្ជា គឺបណ្តាញកិលេសហើយ ។

**គុណេហិ យោ សីលសមាធិបញ្ញា**

**វិមុត្តិញ្ញាណប្បភូតីហិ យុត្តោ**

**ខេត្តញ្ញនានំ កុសលត្ថិកានំ**

**តមរិយសង្ឃំ សិរសា នមាមិ ។**

ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធាទ្រង់
កបដោយគុណសីលត្រង់ និងសមាធិបញ្ញា ។
និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល ។
ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល
ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ ។

# នមស្សការដោយអធិដ្ឋាន

**ឥច្ចេវមច្ចន្ត នមស្សនេយ្យំ**

**នមស្សមានោ រតនត្តយំ យំ**

**បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ**

**តស្សានុភាវេន ហតន្តរាយោ ។**

ខ្ញុំសូមនមស្សការ លើកហត្ថាឱនសិរសី

បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា ។
សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសាធំទូលាយ ។
សូមឱ្យកំចាត់បង់ អពមង្គលទាំងឡាយ
ឱ្យជៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ។
ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ។
ដោយគុណនមស្សការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានហោង ។

# នមស្សការបូជនីយវត្ថុជាទីគោរព

**វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ**
**សារីរិកធាតុមហាពោធឹ ពុទ្ធរូបំ សកលំ សទា ។**

ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី រិកធាតុនៃព្រះពុទ្ធ ។
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំឱនចិត្តបរិសុទ្ធ លើកកម្បង់អញ្ជលី ។

និងព្រះពុទ្ធរូប　　តំណាងអង្គព្រះមុនី
ដែលឋិននៅគ្រប់ទី　　ឋាននានានោះទាំងអស់ ។
( ដោយតេជៈនៃគុណ　　ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលោស់　　រំដោះទុក្ខភ័យអន្តរាយ ។
សូមឱ្យខ្ញុំបានសុខ　　ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ　　សូមឱ្យក្លាយមកជាមិត្ត ។
សូមទាន់ព្រះអរី　　យមេត្រេយ្យថ្លៃវិសិដ្ឋ
សូមបានឃើញធម៌ពិត　　សមដូចចិត្តប្រាថ្នាហោង ) ។

# នមស្សការពុទ្ធបាទ

**វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ តិលោកកេតុំ តិភវេកនាថំ**
**យោ លោកសេដ្ឋោ សកលំ កិលេសំ ឃេត្វាន ពោធេសិ ជនំ អនន្ទំ ។**

ព្រះសម្មាសម្ពុទ្ធឯណា ព្រះអង្គប្រសើរក្នុងលោក ទ្រង់កាត់បង់នូវកិលេស ទាំងអស់បានហើយ ញ៉ាំងជនជាអានន្ទឱ្យត្រាស់ដឹងហើយ ខ្ញុំសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុតអំពីច្រាំងនៃភពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោក មានតែព្រះអង្គមួយ ជាទីពឹងនៃសព្វសត្វក្នុងត្រៃភព ។

**យំ នម្មទាយ នទិយា បុលិនេ ច តីរេ**

**យំ សច្ចពន្ធគិរិកេ សុមនា ច លគ្គេ**

**យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ**

**តំ បាទលញ្ឆនមហំ សិរសា នមាមិ ។**

ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើផ្ទៃខ្សាច់ ទៀបឆ្នេរនៃស្ទឹងឈ្មោះនម្មទា ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើភ្នំសច្ចពន្ធ និងលើភ្នំសុមនកូដ ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) ក្នុងយោនកបុរី ខ្ញុំសូមក្រាបថ្វាយបង្គំ ដោយត្បូងចំពោះទៅព្រះបាទ និងស្នាមព្រះបាទនោះនៃព្រះសក្យមុនី ។

**សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ យោនកបុរេ**

**នម្មទាយ នទិយា បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។**

ខ្ញុំសូមនមស្ការអំពីចម្ងាយ នូវឋានដែលមានព្រះបាទដ៏ប្រសើរ ៥ កន្លែង គឺឋានលើភ្នំសុវណ្ណមាលិកៈ ១ លើភ្នំសុវណ្ណបព៌ត ១ លើភ្នំសុមនកូដ ១ ក្នុងយោនកបុរី ១ ក្បែរស្ទឹងនម្មទា ១ ។

# បត្តិទានគាថា

ពុទ្ធសាសនិកជន ដែលបានធ្វើនូវកុសលឯណាមួយរួចហើយ បើមានប្រាថ្នានឹងឱ្យចម្រើន នូវផលានិសង្សដល់ខ្លួន ដោយច្រើនឡើងទៀតនោះ គប្បីឧទ្ទិសផ្សាយផលនៃកុសលនោះ ដល់សត្វទាំងឡាយ ដោយកុសលចិត្តជាបុញ្ញកិរិយាវត្ថុ១យ៉ាង ដែលហៅថា **បត្តិទាន** គឺកិរិយាឱ្យនូវចំណែកបុណ្យដល់អ្នកដទៃដោយ **បត្តិទានគាថា** ដូច្នេះថា:

**យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម**
**កាយេន វាចាមនសា តិទសេ សុគតំ កតំ**
**យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ**
**កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ**
**យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា**
**យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ**
**សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា**
**មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ ។**

**យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម** អំពើជាកុសលឯណាមួយដែលខ្ញុំគប្បីធ្វើ **កាយេន វាចាមនសា** ដោយទ្វារទាំង ៣ គឺកាយ

វាចា ចិត្ត **តិទសេ សុគតំ កតំ** អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឱ្យទៅកើតក្នុងឋានសួគ៌បាន **យេ សត្តា សញ្ញិនោ អត្ថិ** សត្វទាំងឡាយឯណា គឺមនុស្ស ឬទេវតា ឬព្រហ្ម ដែលជាសត្វមានសញ្ញាក្តី **យេ ច សត្តា អសញ្ញិនោ** សត្វទាំងឡាយឯណា ជាអសញ្ញីសត្វ គឺសត្វដែលឥតសញ្ញាក្តី **កតំ បុញ្ញផលំ មយ្ហំ សព្វេភាគី ភវន្តុ តេ** សត្វទាំងឡាយទាំងអស់នោះ ចូរឱ្យបានទូវចំណែកផលនៃបុណ្យ ដែលខ្ញុំបានធ្វើហើយ បានឧទ្ទិសផ្សាយឱ្យទៅនេះចុះ **យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា** បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណា បានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឱ្យបានសោយនូវផលនៃបុណ្យ ដែលខ្ញុំបានឧទ្ទិសទៅឱ្យនោះចុះ **យេ ច តត្ថ ន ជានន្តិ** ម៉្យាងទៀត បណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណាមិនបានដឹងនូវបុណ្យដែលខ្ញុំបានធ្វើហើយនោះ **ទេវា គន្ត្វា និវេទយុំ** សូមទេវតាទាំងឡាយ អញ្ជើញទៅឱ្យដំណឹងដល់សត្វទាំងឡាយនោះ ឱ្យបានដឹងផងថា ជនឯណោះ គេបានធ្វើបុណ្យហើយ គេឧទ្ទិសផ្សាយផលបុណ្យនោះ មកដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរអនុមោទនាត្រេកអរ នឹងបុណ្យគេទាំងនោះចុះ **សព្វេ លោកម្හិ យេ សត្តា ជីវន្តាហារហេតុកា** សត្វទាំងឡាយឯណា ក្នុង

លោកទាំងអស់ ដែលអាស្រ័យនូវអាហារហើយរស់នៅ **មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ** សត្វទាំងឡាយទាំងអស់នោះ ចូរឱ្យបាននូវភោជនជាទីគាប់ចិត្តដែលសម្រេចដោយបុញ្ញឫទ្ធិ តាមចិត្តដែលខ្ញុំឧទ្ទិសផ្សាយទៅឱ្យនេះចុះ ។

# យំកិញ្ចិ ប្រែពាក្យកាព្យ

| | |
|---|---|
| កម្មកុសលឯណា | ដែលជាការឥតសៅហ្មង |
| យើងខ្ញុំបានកសាង | ដោយទ្វារកាយវាចាចិត្ត ។ |
| កុសលទាំងអស់នោះ | អាចជួយដោះជួយបង្ខិត |
| នាំសត្វឱ្យជាប់ចិត្ត | ស្ថិតនៅនាស្ថានឧត្តម ។ |
| សត្វណាមានសញ្ញា | មនុស្សទេវតាឬឥន្ទព្រហ្ម |
| ដែលមានស័ក្តិតូចធំ | ព្រមទាំងសត្វឥតសញ្ញា ។ |
| សូមបានចំណែកបុណ្យ | ដែលជាគុណល្អថ្លៃថ្លា |
| យើងខ្ញុំបានរចនា | ចាត់ចែងការកុសលហ្នឹង ។ |
| ម្យ៉ាងទៀតសត្វឯណា | ឆ្ងាយអស្ចារ្យពុំបានដឹង |
| សូមទេវតាទៅប្តឹង | ឱ្យដំណឹងយ៉ាងនេះថា ។ |
| នរជននៅឯនុះ | ស្រីឬប្រុសបានជ្រះថ្លា |

កសាងបុញ្ញកិរិយា　　វត្តុជាផ្លូវឆើតឆាយ ។
ហើយគេឧទ្ទិសផល　　ឱ្យបានដល់អ្នកទាំងឡាយ
ចូរមានចិត្តស្រាស់ស្រាយ　　បន្ទន់កាយទទួលយក ។
សត្វលោកទាំងអស់នោះ　　ដែលបានរស់តរៀងមក
ដោយបានបរិភោគ　　នូវអាហារទើបរស់បាន ។
សត្វទាំងអស់នោះណា　　បានសុខាសព្វគ្រប់ប្រាណ
អាហារយ៉ាងចំណាន　　សូមឱ្យបានកុំខានឡើយ ។

# ចប់នមស្សការព្រះរតនត្រៃ

តមេវ វាចំ ភាសេយ្យ　　យាយត្តានំ ន តាបយេ
បរេ ច ន វិហឹសេយ្យ　　សា វេ វាចា សុភាសិតា ។

បុគ្គលមិនធ្វើខ្លួនឲ្យក្តៅក្រហាយដោយវាចាណា គប្បីពោលនូវវាចានោះ និងម្យ៉ាងទៀត បុគ្គលមិនបានបៀតបៀនពួកជនដទៃដោយវាចាណា វាចាទាំងអស់នោះឯង ជាសុភាសិត ។

# បុព្វភាគប្បដិបត្តិ (កិច្ចបដិបត្តិខាងដើម)

បុរសស្ត្រីដែលមានសទ្ធាជ្រះថ្លា ក្នុងគុណព្រះរតនត្រ័យ គឺគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហើយមានប្រាថ្នានឹងប្តេជ្ញាខ្លួនជាឧបាសក ឬ ជាឧបាសិកា ជាបព្វភាគបដិបត្តិ គឺសេចក្តីប្រតិបត្តិជាចំណែកខាងដើម ឱ្យបានពេញស័ប់ជាអ្នកកាន់ព្រះពុទ្ធសាសនា ឬជាអ្នកតម្កល់នៅក្នុងព្រះពុទ្ធសាសនានោះ ដំបូងបង្អស់ត្រូវបញ្ចេញវចីភេទ សូមខមាទោសនឹងព្រះរតនត្រ័យ ក្នុងទីចំពោះព្រះភក្ត្រព្រះពុទ្ធរូបក៏បាន ចំពោះព្រះស្តូប ឬព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះសម្មាសម្ពុទ្ធក៏បាន ឬក៏ចំពោះមុខភិក្ខុ ១ រូបក្តី ២ រូបក្តី ៣ រូបក្តីក៏បាន ឬក៏ចំពោះមុខព្រះសង្ឃ[1] គឺភិក្ខុទាំងឡាយតាំងពី ៤ រូបឡើងទៅក៏បាន លុះសូមខមាទោសរួចហើយ ត្រូវបញ្ចេញវចីភេទពោលប្រកាសប្តេជ្ញាខ្លួន ឱ្យជាអ្នកបានដល់ព្រះត្រៃសរណគមន៍ ជាឧបាសក ឬ ជាឧបាសិកា ក្នុងព្រះពុទ្ធសាសនាជាខាងក្រោយ រួចហើយត្រូវសមាទាននិច្ចសីលរក្សាឱ្យខ្ជាប់តទៅ, បើមានសទ្ធាជ្រះថ្លាក៏គប្បីរក្សាឧបោសថ

[1] ភិក្ខុឬសាមណេរ ១ រូបក៏ដោយឱ្យតែតាំងចិត្តថា សង្ឃក៏បាន ព្រោះមិនជាសង្ឃកម្ម ។

សីល តាមកាលកំណត់ដែលត្រូវរក្សាម្តងៗនោះផងនឹងមានផលានិសង្សច្រើនជាលំដាប់ៗ ឡើងទៅ ។

ឯពាក្យសូមខមាទោសនឹងព្រះរតនត្រ័យនោះ ក្នុងទីនេះសូមរៀបរៀងតែវិធីខមាទោសចំពោះមុខព្រះសង្ឃប៉ុណ្ណោះ

- **បើបុរសតែម្នាក់ ត្រូវសូធ្យថា :**

➢ **អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមុឡ្ហំ យថាអកុសលំ យោហំ ភន្តេ កាយេន វា វាចាយ វា មនសា វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អកាសឹ តស្ស មេ ភន្តេ សង្ឃោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ ។**

បពិត្រព្រះសង្ឃដ៏ចម្រើន ទោសកំហុសដែលប្រព្រឹត្តកន្លង គ្របសង្កត់ហើយ នូវខ្ញុំព្រះករុណា តាមដោយខ្ញុំព្រះករុណា ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះសង្ឃដ៏ចម្រើន ក្រែងខ្ញុំព្រះករុណា បានធ្វើហើយ នូវសេចក្តីល្មើស មិនគោរពដល់ព្រះពុទ្ធជាម្ចាស់ក្តី ដល់ព្រះធម៌ក្តី ដល់ព្រះសង្ឃក្តី ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃ អត់នូវទោសកំហុសនោះ ដល់ខ្ញុំព្រះករុណា ព្រោះអំពើនៃទោសនោះ ជា

សេចក្ដីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឱ្យល្អ តទៅក្នុងខាងមុខនោះហោង ។

- បើស្ត្រីតែម្នាក់ ត្រូវសូធ្យថា :

➢ **អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមុឡ្ហំ យថាអកុសលំ យាហំ ភន្តេ កាយេន វា វាចាយ វា មនសា វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អកាសឹ តស្សា មេ ភន្តេ សង្ឃោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ ។**

(ប្រែដូចគ្នានឹងបុរសម្នាក់ខាងលើ )

- បើបុរសច្រើននាក់ ត្រូវសូធ្យថា :

➢ **អច្ចយោ នោ ភន្តេ អច្ចគមា យថាពាលេ យថាមុឡ្ហេ យថាអកុសលេ យេ មយំ ភន្តេ កាយេន វា វាចាយ វា មនសា វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អករិម្ហា តេសំ នោ ភន្តេ សង្ឃោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ ។**

បពិត្រព្រះសង្ឃដ៏ចម្រើន ទោសកំហុសដែលប្រព្រឹត្តកន្លង គ្របសង្កត់ហើយ នូវខ្ញុំព្រះករុណាទាំងឡាយ តាមដោយខ្ញុំព្រះករុណា

ទាំងឡាយ ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រព្រះសង្ឃដ៏ចម្រើន ក្រែងខ្ញុំព្រះករុណាទាំងឡាយ បានធ្វើហើយ នូវសេចក្តីល្មើស មិនគោរពដល់ព្រះពុទ្ធជាម្ចាស់ក្តី ដល់ព្រះធម៌ក្តី ដល់ព្រះសង្ឃក្តី ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃ អត់នូវទោសកំហុសនោះ ដល់ខ្ញុំព្រះករុណាទាំងឡាយ ព្រោះអំពើនៃទោសនោះ ជាសេចក្តីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឱ្យល្អ តទៅក្នុងខាងមុខនោះហោង ។

- បើស្រ្តីច្រើននាក់ ត្រូវសូធ្យថា :

➢ **អច្ចយោ នោ ភន្តេ អច្ចគមា យថាពាលា យថាមុឡ្ហា យថាអកុសលា យា មយំ ភន្តេ កាយេន វា វាចាយ វា មនសា វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អករិម្ហា តាសំ នោ ភន្តេ សង្ឃោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ ។**

(ប្រែដូចគ្នានឹងបុរសច្រើននាក់ខាងលើ ) ។

- បើបុរសនិងស្រ្តីច្រើននាក់លាយគ្នា តាំងពីពីរនាក់ឡើងទៅ

សូមខមាទោសព្រមគ្នានោះ ត្រូវសូធ្យថា :

- **អច្ចយោ នោ ភន្តេ អច្ចគមា យថាពាលេ / យថាពាលា / យថាមុឡ្ហេ / យថាមុឡ្ហា / យថាអកុសលេ / យថាកុសលា / យេ / យា / មយំ ភន្តេ កាយេន វា វាចាយ វា មនសា វា ពុទ្ធស្ស វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អករិម្ហា / តេសំ / តាសំ / នោ ភន្តេ សង្ឃោ អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយ ។**

(ប្រែដូចគ្នានឹងបុរសច្រើននាក់ខាងលើ ) ។

ព្រះសង្ឃដែលនៅទីនោះ ត្រូវទទួលថា **សាធុ** (ប្រែថា ) ប្រពៃហើយ ។

បុរសត្រូវថា **យថាពាលេ យថាមុឡ្ហេ យថាអកុសលេ / យេ មយំ / តេសំ នោ ។**

បើស្ត្រីត្រូវថា **យថាពាលា យថាមុឡ្ហា យថាអកុសលា /យា មយំ / តាសំ នោ ។**

( បាលីក្រៅពីនេះ ថាដូចគ្នាទាំងអស់ តែលោកអ្នកលំបាក ពោលបាលី នឹងពោលតែសម្រាយក៏បាន ) ។

លុះបានសូមខមាទោសនឹងព្រះរតនត្រ័យដូច្នេះរួចហើយ គប្បីបញ្ចេញវចីភេទប្ដេជ្ញាខ្លួនជាអ្នកដល់ព្រះត្រ័យសរណគមន៍ គឺព្រះពុទ្ធ

ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭក ដើម្បីនឹងឱ្យឡើងជានាមបញ្ញត្តិជា **ឧបាសក** ឬជា **ឧបាសិកា** ក្នុងព្រះពុទ្ធសាសនាតទៅ, ឯប្ដេជ្ញាខ្លួននោះនឹងប្ដេជ្ញា ក្នុងទីចំពោះព្រះភក្ត្រព្រះពុទ្ធរូបក៏បាន ចំពោះព្រះស្ដូប ឬព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះដ៏មានបុណ្យក៏បាន ចំពោះមុខបុគ្គល ឬ គណៈ ឬសង្ឃក៏បាន ។

ឯពាក្យសូធ្យប្ដេជ្ញាខ្លួនចំពោះព្រះរតនត្រ័យនោះ ក្នុងទីនោះ សូមរៀបរៀងតែវិធីប្ដេជ្ញាខ្លួនចំពោះមុខព្រះសង្ឃប៉ុណ្ណោះ

- បើបុរសតែម្នាក់ ត្រូវប្ដេជ្ញាដោយពាក្យថា :

➢ **ឯសាហំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ សង្ឃោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។**

ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាសូមដល់នូវព្រះដ៏មានព្រះភាគ ដែលទ្រង់បរិនិព្វានទៅ អស់កាលយូរអង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះសង្ឃជ្រាបនូវខ្ញុំព្រះករុណាថា ជាឧបាសក បានដល់ហើយនូវព្រះរតនត្រ័យជាទីពឹងទីរឭក ស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

- បើស្ត្រីតែម្នាក់ ត្រូវប្តេជ្ញាដោយពាក្យថា :

➢ **ឯសាហំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសិកំ មំ សង្ឃោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។**

( ប្រែដូចបុរសម្នាក់ខាងលើ គ្រាន់តែប្តូរជា ឧបាសិកា ) ។

- បើបុរសច្រើននាក់ ត្រូវប្តេជ្ញាដោយពាក្យថា :

➢ **ឯតេ មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ នោ សង្ឃោ ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណំ គតេ ។**

ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមដល់នូវព្រះដ៏មានព្រះភាគ ដែលទ្រង់បរិនិព្វានទៅ អស់កាលយូរអង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះសង្ឃ ជ្រាបនូវខ្ញុំព្រះករុណាទាំងឡាយថា ជាឧបាសក បានដល់ហើយនូវព្រះរតនត្រ័យជាទីពឹងទីរឭក ស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

- បើស្ត្រីច្រើននាក់ ត្រូវប្តេជ្ញាដោយពាក្យថា :

- **ឯតេ មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសិកាយោ នោ សង្ឃោ ធារេតុ អជ្ជតគ្គេ បាណុបេតា សរណំ គតា ។**

( ប្រែដូចបុរសច្រើននាក់ខាងលើ គ្រាន់តែប្តូរជា ឧបាសិកា ) ។

- បើបុរសស្ត្រីច្រើននាក់ ត្រូវប្តេជ្ញាដោយពាក្យថា :

- **ឯតេ មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ / ឧបាសិកាយោ នោ សង្ឃោ ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណំ គតេ / បាណុបេតា សរណំ គតា ។**

( ប្រែដូចបុរសច្រើននាក់ខាងលើ គ្រាន់តែប្តូរជា ឧបាសក ឧបាសិកា ។ រួចបុគ្គលឬគណៈ ឬសង្ឃ ត្រូវទទួលថា **សាធុ** (ប្រែថា) ប្រពៃហើយ ។

- បើបុរសតែម្នាក់ ឬស្ត្រីតែម្នាក់ ហើយសូមប្តេជ្ញាខ្លួនចំពោះព្រះពុទ្ធរូប ឬព្រះស្តូប ឬព្រះចេតិយ ដែលបញ្ចុះ ព្រះសារីរិកធាតុព្រះដ៏មានបុណ្យនោះ ត្រូវពោលប្តេជ្ញាដោយពាក្យថា :

- **ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ / ឧបាសិកំ / មំ សង្ឃោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។**

ប្រែថា បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណា សូមដល់នូវព្រះដ៏មានព្រះភាគផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះករុណាថាជា ឧបាសក / ឧបាសិកា បានដល់ហើយនូវព្រះរតនត្រ័យ ជាទីពឹងទីរឭកស្មើដោយជីវិត តាំងពីថ្ងៃនេះ ជាដើមរៀងទៅ ។

បើគ្នាច្រើន ក៏ត្រូវសូធ្យដូចន័យមុន ខុសតែត្រង់ ពាក្យថា **ភគវន្តំ** ថា **ភគវា** ប៉ុណ្ណោះ, បើគ្នាច្រើន ហើយនឹងសូធ្យប្ដេជ្ញាខ្លួនព្រមគ្នា ដោយពាក្យជាឯកវចនៈក៏បាន ព្រោះសូធ្យព្រមទាំងអស់គ្នា ។

បុរស ឬ ស្ត្រី កាលបើបានពោលពាក្យប្ដេជ្ញាខ្លួន ជាអ្នកបានដល់ព្រះត្រៃសរណគមន៍ ដូច្នេះរួចហើយ ក៏បាននាមបញ្ញត្តិថា **“ឧបាសក”** ឬ **“ឧបាសិកា”** ក្នុងខណៈនោះឯង ។

វិធីសូមខមាទោសក្តី វិធីសូមប្ដេជ្ញាខ្លួនជាឧបាសក ជា ឧបាសិកាក្ដីបើអ្នកដែលមិនចេះសូធ្យជាបាលី នឹងសូធ្យជាសេចក្ដីសម្រាយ

តាមភាសារបស់ខ្លួននោះក៏បាន បើចេះសូធ្យទាំងបាលី ទាំងសេចក្ដីប្រែសម្រាយផង ដូចបានពោលមកហើយនោះ ជាការប្រពៃពិត តែកុំសូធ្យតែបាលីទទេ ដោយមិនដឹងថាជាអ្វីនោះឡើយ ព្រោះកិច្ចដែលសូធ្យខមាទោសនិងប្ដេជ្ញាខ្លួននោះចំពោះយកសទ្ធា គឺសេចក្ដីជឿជាក់ និងបញ្ញាជាសម្មាទិដ្ឋិ ដែលដឹងពិត យល់ត្រូវពិត ជាប្រមាណ ។ ( **ចប់បុព្វភាគបដិត្តិតែប៉ុណ្ណោះ** )

# ឧបាសកនិទ្ទេស

## សម្ដែងអំពីនាមថា ឧបាសកនិងធម៌របស់ឧបាសកមានសីលជាដើម

ជនដែលមាននាមបញ្ញត្តិថា **ឧបាសក ឧបាសិកា** នោះ ដោយហេតុដែលបានចូលទៅជិត ដល់នូវព្រះរតនត្រ័យ ជាទីពឹងទីរឭក ដូចពុទ្ធភាសិតដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្ដែងចំពោះមហានាមសក្យរាជថា “ម្នាលមហានាម គ្រហស្ថឯណាមួយបានដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭក គ្រហស្ថនោះឯង បានឈ្មោះថា **ឧបាកស** បើស្ត្រីហៅថា **ឧបាសិកា**” ។

ម្យ៉ាងទៀត មានបាលីថា **រតនត្តយំ ឧបាសតីតិ ឧបាសកោ** ជនឯណា ចូលទៅអង្គុយជិតព្រះរតនត្រ័យ ព្រោះហេតុនោះ ជននោះ ឈ្មោះថា **ឧបាសក** ។

អធិប្បាយថា ជនដែលចូលទៅអង្គុយជិតព្រះរតនត្រ័យនោះ គឺមិនមែនជាអ្នកចូលទៅអង្គុយជិតព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជានិច្ច ដោយរូបកាយនោះទេ គឺលោកសង្គ្រោះ យកនាមកាយជាប្រមាណ, សូម្បីជននោះ ស្ថិតនៅក្នុងទីឆ្ងាយប៉ុន្មាន តែមានសន្តានចិត្តប្រព្រឹត្តជាប់នៅ ក្នុងគុណព្រះរតនត្រ័យជានិច្ច, ចិត្តនោះឱនទៅតោងយកគុណព្រះរតនត្រ័យ ជាទីពឹងទីរឭកជានិច្ចហើយ ជននោះឈ្មោះថាបានចូលទៅអង្គុយជិតព្រះរតនត្រ័យជានិច្ច, បើគ្រាន់តែចូលទៅអង្គុយជិតព្រះពុទ្ធ ដោយរូបកាយ តែសន្តានចិត្តនោះ ស្ថិតនៅក្នុងទីឆ្ងាយអំពីគុណព្រះរតនត្រ័យ មិនបង្អោនចិត្តទៅក្នុងគុណព្រះរតនត្រ័យទេ ជននោះ ឈ្មោះថា ស្ថិតនៅឆ្ងាយអំពីគុណព្រះរតនត្រ័យ មិនមែនជា **“ឧបាសក, ឧបាសិកា”** ឡើយ ។

# សីលនៃឧបាសក

បញ្ចវិរតិចេតនា គឺចេតនាដែលវៀរចាកវេរា ៥ ឈ្មោះថាជា “សីលនៃឧបាសក” ដូចមានពុទ្ធភាសិតដែលព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់សម្តែងចំពោះមហានាមសក្យរាជថា “ ម្នាលមហានាម ឧបាសកឯណា បានវៀរចាក **បាណាតិបាត** គឺមិនសម្លាប់សត្វ១ វៀរចាក **អទិន្នាទាន** គឺមិនលួចទ្រព្យអ្នកដទៃ១ វៀរចាក **កាមេសុមិច្ឆាចារ** គឺមិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ១ វៀរចាក **មុសាវាទ** គឺមិននិយាយកុហក១ វៀរចាក **សុរាមេរយៈ** គឺមិនផឹកនូវសុរានិងមេរ័យ១ ឧបាសកនោះ ឈ្មោះថា **ឧបាសកមានសីល**” ។

# វិធីសមាទាននិច្ចសីល

ពុទ្ធសាសនិកជន ដែលបានដល់នូវព្រះត្រៃសរណគមន៍ បានឡើងនាមជាឧបាសក ឬឧបាសិកាហើយ កាលបើនឹងសមាទាន(ការទទួលកាន់យក)នូវនិច្ចសីល គឺសីល ៥ ជាបច្ចេកសមាទាន អំពីបុគ្គលដទៃ គឺភិក្ខុ ឬសាមណេរនោះ គប្បីសូធ្យនមស្ការថ្វាយបង្គំរឭកដល់គុណព្រះរតនត្រៃដោយសង្ខេបជាមុន រួចហើយត្រូវសូមនូវនិច្ចសីល

ព្រមទាំងព្រះត្រៃសរណគមន៍ ចំពោះភិក្ខុ ឬសាមណេរដែលខ្លួននឹងសមាទាននោះថា:

**ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាម ។**

**ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាម ។**

**តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចាម, អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។**

ប្រែថា : សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥ មួយអន្លើដោយត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា, ជាគម្រប់ពីរដងផង, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវនិច្ចសីលប្រកបព្រមដោយអង្គ ៥

មួយអន្លើដោយត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា, ជាកម្រប់បីដងផង, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។

( សូមដូច្នេះក៏បាន តាមសេចក្តីពេញចិត្តរបស់អ្នកសូម )

**ឧកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាម ។**

**ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាម ។**

**តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាម ។**

ប្រែថា : សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលប្រកបព្រមដោយ ៥ មួយអន្លើដោយត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលប្រកបព្រមដោយ ៥ មួយអន្លើដោយត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា, ជាគម្រប់ពីដងផង, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា

ទាំងឡាយ សូមនូវសីលប្រកបព្រមដោយ ៥ មួយអន្លើដោយត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា, ជាកម្រប់បីដងផង

លុះសូមដូច្នេះរួចហើយ លោកអ្នកឱ្យ សីល លោកសូធ្យ **នមោ ៣**ចប់ ហើយលោកឱ្យព្រះត្រៃសរណគមន៍និងនិច្ចសីល, អ្នកសមាទាន ត្រូវទទួលថាតាមលោក ដោយបញ្ចេញវចីភេទឱ្យ ឮច្បាស់លាស់, កុំទទួលខ្សឹបៗ ។

**លោកបង្រៀនសិក្ខាបទសូធ្យថា :**

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (សូធ្យ ៣ដង )

ប្រែថា : វីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណាចូលមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

**ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរឭក ។

**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹងទីរឭក ។

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃ ជាទីពឹងទីរឭក ។

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង។

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃ ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ ជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃ ជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

ហើយព្រះសង្ឃពោលថា **តិសរណគ្គហណំ បរិបុណ្ណំ**

ប្រែថា : កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍បរិបូណ៌តែប៉ុណ្ណេះ ។

អ្នកទទួលពោលថា **អាម ភន្តេ** ប្រែថា : ករុណាលោកម្ចាស់ ។

ហើយលោក ឱ្យនិច្ចសីល ជាបច្ចេកសមាទានថា :

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬ ដោយវាចា ។

**កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

**មុសាវាទា វេរមណី សិក្ខាបទំ សមាទយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ។

**ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ** ប្រែថា : អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៥ នេះ ឱ្យប្រពៃ ត្រូវរក្សាឱ្យល្អអស់កាលជានិច្ចដោយមិនប្រមាទ គឺថា កុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទានត្រូវពោលថា **អាម ភន្តេ** ករុណាលោកម្ចាស់ ហើយលោកសម្តែងអានិសង្សសីលឱ្យស្តាប់តទៅ ទៀតថា :

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**
**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។**

ប្រែថា : សត្វទាំងឡាយទៅកាន់ស្ថានសួគ៌បាន ក៏ព្រោះសីល, សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល, សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខ ពោលគឺ ព្រះនិព្វានក៏ព្រោះសីល, ព្រោះហេតុនោះ បុគ្គលជាសប្បុរសទាំងឡាយ គប្បីជំរះនូវសីលឱ្យបរិសុទ្ធកុំឱ្យសៅហ្មងឡើយ ។**(ឬ ជាគាថាផ្សេងៗក៏បាន ដែលជាអានិសង្សសីល)**

អ្នកសមាទានត្រូវពោលថា **សាធុ** ប្រែថា : ប្រពៃហើយ ។

( វិធីសមាទាននិច្ចសីលជាបច្ចេកសមាទាន ចប់តែប៉ុណ្ណោះ )

# វិធីសមាទានឧបោសថសីល

ឧបាសក ឧបាសិកា ជាអ្នករក្សានូវឧបោសថសីល កាលបើដល់ថ្ងៃជិតនឹងរក្សានូវឧបោសថសីល គឺ មុន ១ ថ្ងៃដែលកំណត់ថាព្រឹកឡើងនឹងរក្សានូវឧបោសថសីលនោះ គប្បីចាត់ចែងការងារដែលគួរនឹងចាត់ចែង មានចាត់ចែងអាហាជាដើម ដែលជាការងារ គឺខ្លួនត្រូវធ្វើ ឬនឹងប្រើឱ្យគេធ្វើ ក្នុងថ្ងៃស្អែក គឺក្នុងថ្ងៃឧបោសថកាលឱ្យហើយក្នុងថ្ងៃនោះជាមុន តែកុំចាត់ចែងការងារដែលមិនប្រកបដោយធម៌ ដែលជាការងារ គឺខ្លួនជាឧបាសក ឧបាសិកា មិនគួរនឹងចាត់ចែងនោះឡើយ, លុះដល់ព្រឹកឡើងជាថ្ងៃឧបោសថ កាលត្រូវ រក្សានូវឧបោសថសីល គប្បីភ្ញាក់ឡើងអំពីព្រលឹម ហើយខ្ពុរមាត់ជំរះធ្មេញឱ្យស្អាតរួចហើយ បើបានសមាទាននូវឧបោសថសីលក្នុងវេលានោះ ក៏ជាការប្រពៃ បើឃើញថា នឹងសមាទានពីព្រលឹមនោះមិនទាន់ទេ ក៏គប្បីកំណត់នូវឧបោសថកាល គឺកាលជាទីរក្សានូវឧបោសថសីល ក្នុង ១ថ្ងៃ ១យប់នោះ ដោយបញ្ចេញវាចាអធិដ្ឋានដោយថា៖

**អជ្ជ ឧបោសថោ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ**

**ឧបោសថិកោ / ឧបោសិកា / ភវិស្សាមិ**

ប្រែថា : ថ្ងៃនេះ ជាថ្ងៃត្រូវរក្សាទូវឧបោសថសីល, ខ្ញុំនអញនឹងជាអ្នករក្សាទូវឧបោសថសីលអស់ថ្ងៃនេះ នឹងយប់នេះ ។

បើឧបាសក ត្រូវថា **ឧបោសថិកោ** បើឧបាសិកា ត្រូវថា **ឧបោសថិកា ។**

បើមិនចេះបាលី និងអធិដ្ឋានតាមភាសារបស់ខ្លួនៗ ក៏គួរដោយពិតលុះអធិដ្ឋានកំណត់កាលដូច្នេះហើយ រួចហើយត្រូវតាំង**វិរតិចេតនា**វៀរចាកសីលភេទ គឺហេតុដែលជាទីទំលាយនូវសីលនោះៗ ឱ្យគ្រប់សិក្ខាបទទាំង ៨ កាលបើបានអធិដ្ឋានដូច្នេះរួចហើយ តអំពីពេលនោះមក ក៏គប្បីសមាទាននូវឧបោសថសីល អំពីភិក្ខុជាដើមតាមកាលដ៏គួរចុះ បើទុកជាដល់ព្រះអាទិត្យរះខ្ពស់ឡើង ប្រមាណពេញពន្លឺខ្លាំង ទើបបានសមាទានក្តី ក៏ឈ្មោះថា បានសមាទានដោយប្រពៃ ឈ្មោះថាបានរក្សានូវឧបោសថសីល ពេញកាលកំណត់ ១ ថ្ងៃ ១ យប់ ដោយបរិបូណ៌ ព្រោះអ្នកសមាទាន បានធ្វើនូវឧបោសថកាលមិនឱ្យខ្វះខាតទាំង**វិរតិចេតនា**សោត ក៏កើតខ្លាំងក្លាបរិបូណ៌ក្នុងសន្តាននឹងបានផលា-និសង្សច្រើន ។

កាលបើឧបាសក ឧបាសិកា នឹងសមាទាននូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ ជាបច្ចេកសមាទានអំពីបុគ្គលដទៃ គឺ ភិក្ខុ

ឬសាមណេរនោះ គប្បីសូធ្យនមស្ការថ្វាយបង្គំរឭកដល់គុណព្រះរតនត្រ័យដោយសង្ខេប ជាមុនរួចហើយ ត្រូវសូមនូវឧបោសថសីល ព្រមទាំងព្រះត្រ័យសរណគមន៍ ចំពោះភិក្ខុ ឬសាមណេរ ដែលខ្លួនត្រូវសមាទាននោះ ដោយពាក្យថា :

**ឧកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម ។**

**ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម ។**

**តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម, អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។**

ប្រែថា : សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយត្រៃសរណគមន៍ ដើម្បី

ប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា, ជាគម្រប់ពីរដងផង, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវឧបោសថសីលប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា, ជាគម្រប់បីដងផង, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ខ្ញុំព្រះករុណាទាំងឡាយ ។

( ឬក៏សូមដូច្នេះក៏បាន តាមសេចក្តីពេញចិត្តរបស់អ្នកសូម )

**ឧកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ យាចាម ។**

**ទុតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ យាចាម ។**

**តតិយម្បិ មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ យាចាម ។**

ប្រែថា : សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា, បពិត្រព្រះករុណាដ៏

ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា, ជាគម្រប់ពីដងផង, បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណាទាំងឡាយ សូមនូវសីលប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា ជាកម្រប់បីដងផង ។

លោកបង្រៀនសិក្ខាបទសូធ្យថា :

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (សូធ្យ ៣ដង )

ប្រែថា : វីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណាចូលមានដល់ព្រះដ៏-មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

**ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ។

**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពួងទីរឭក ។

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃ ជាទីពួងទីរឭក ។

**ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

**ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង។

**ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីពួងទីរឭក ជាគម្រប់ពីរដងផង ។

**តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

**តតិយម្បិ ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ ជាទី ពួងទីរឭក ជាគម្រប់បីដងផង ។

**តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃ ជាទីពួងទីរឭក ជាគម្រប់បីដងផង ។

ហើយព្រះសង្ឃពោលថា **តិសរណគ្គហណំ បរិបុណ្ណំ**

ប្រែថា ៖ កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍បរិបូណ៌តែប៉ុណ្ណេះ ។

អ្នកទទួលពោលថា **អាម ភន្តេ** ប្រែថា ៖ ករុណាលោកម្ចាស់ ។

ហើយលោក ឱ្យនូវឧបោសថសីល ជាបច្ចេកសមាទានថា ៖

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬ ដោយវាចា ។

**អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម ។

**មុសាវាទា វេរមណី សិក្ខាបទំ សមាទយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និង មេរ័យ ។

**វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស ។

**នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយារាំ និងច្រៀង និងប្រគំ និងមើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ និងកិរិយាទ្រទ្រង់ និងប្រដាប់តាក់តែងស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។

**ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។

រួចហើយអ្នកសមាទាន សូធ្យកំណត់ឧបោសថកាលថា

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច**

**រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ។**

ប្រែថា : ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ដ៏ប្រកបព្រមដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តទុក

ហើយនេះ ដើម្បីនឹងរក្សាឱ្យបរិបូណ៌ប្រពៃអស់កាលកំណត់ថ្ងៃនេះ និងយប់នេះ សូមកុសលចូលជាឧបនិស្ស័យ ធ្វើឱ្យច្បាស់នូវព្រះនិព្វាន ក្នុងអនាគតទៅ ឯមុខនោះហោង ។

( រួចហើយលោកឱ្យសីល លោកពោលដាស់តឿនក្រើនរំឭកថា )

**ឥមានិ អដ្ឋ សិក្ខាបទានិ ឧបោសថសីលវសេន ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ ។**

ប្រែថា : អ្នកទាំងឡាយ គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៨ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អដោយអំណាចនៃឧបោសថសីល អស់កាលកំណត់ត្រឹម ១ ថ្ងៃ ១ យប់ នេះ ដោយសេចក្តីមិនប្រមាទ គឺថា កុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទានត្រូវពោលថា **អាម ភន្តេ**

ប្រែថា : ករុណាលោកម្ចាស់

ហើយលោកសម្តែងអានិសង្សសីលឱ្យស្តាប់តទៅ ទៀតថា :

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា**

**សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។**

ប្រែថា : សត្វទាំងឡាយទៅកាន់ស្ថានសួគ៌បាន ក៏ព្រោះសីល, សត្វទាំងឡាយបានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល, សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខ ពោលគឺ ព្រះនិព្វានក៏ព្រោះសីល, ព្រោះហេតុនោះ បុគ្គលជាសប្បុរសទាំងឡាយ គប្បីជំរះនូវសីលឱ្យបរិសុទ្ធកុំឱ្យសៅហ្មងឡើយ ។

អ្នកសមាទានត្រូវពោលថា **សាធុ** ប្រែថា : ប្រពៃហើយ ។

( វិធីសមាទាននិច្ចសីលជាបច្ចេកសមាទាន ចប់តែប៉ុណ្ណោះ )

**សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ**
**សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ**

*(ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ពេលនោះ) ឈ្មោះថា ជានក្ខនត្តឫក្សល្អ ជាមង្គលល្អ ជាពេលភ្លឺស្វាងល្អ ជាពេលនៃអរុណរះល្អ ជាខណៈល្អ ជាយាមល្អ (ទានដែលបុគ្គលបានបូជាហើយ) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះ) ឈ្មោះថាជាគ្រឿងបូជាល្អ ។*

# អង្គនៃសិក្ខាបទ ក្នុងនិច្ចសីល

- **បាណាតិបាត មានអង្គ ៥ :**

១ - **បាណោ** សត្វមានជីវិត ។

២ - **បាណសញ្ញិតា** សេចក្ដីដឹងថាសត្វមានជីវិត ។

៣ - **វធកចិត្តំ** គិតនឹងសម្លាប់ ។

៤ - **ឧបក្កមោ** ព្យាយាមនឹងសម្លាប់ ។

៥ - **តេនមរណំ** សត្វស្លាប់ដោយព្យាយាមនោះ ។

- **អទិន្នាទាន មានអង្គ ៥ :**

១ - **បរបរិគ្គហិតំ** ទ្រព្យមានម្ចាស់របស់គេហួងហែងរក្សា

២ - **បរបរិគ្គហិតសញ្ញិតា** សេចក្ដីដឹងថាទ្រព្យមានម្ចាស់របស់គេហួងហែងរក្សា ។

៣ - **ថេយ្យចិត្តំ** ចិត្តនឹងលួច ។

៤ - **ឧបក្កមោ** ព្យាយាមនឹងលួច ។

៥ - **តេន ហរណំ** លួចបានមកដោយព្យាយាមនោះ ។

- **កាមេសុមិច្ឆាចារ ៤ :**

**១ - អគមនីយដ្ឋានំ** ស្ត្រីដែលមិនគួរនឹងគប់រក គឺស្ត្រីដែលមានគេហួងហែងរក្សា ។

**២ - តស្មឹ សេវនចិត្តំ** គិតនឹងសេពនូវមេថុនធម្មនឹងស្ត្រីនោះ

**៣ - ឧបក្កមោ** ព្យាយាមនឹងសេពនូវមេថុនធម្មនោះ ។

**៤ - មគ្គេនមគ្គប្បដិបាទនំ** ញុំាងមគ្គនិងមគ្គឱ្យដល់គ្នា ។

- **មុសាវាទ មានអង្គ ៤ :**

**១ - អតថំ វត្ថុ** វត្ថុមិនពិត ។

**២ - វិសំវាទនចិត្តំ** គិតនឹងពោលឱ្យខុស ។

**៣ - តជ្ជោ វាយាមោ** ព្យាយាមនឹងពោលឱ្យខុស ។

**៤ - បរស្ស តទត្ថវិជាននំ** ញុំាងអ្នកដទៃឱ្យដឹងច្បាស់នូវសេចក្តីនោះ ។

- **សុរាមេរយ មានអង្គ ៤ :**

**១ - មជ្ជនីយវត្ថុ** វត្ថុជាទីតាំងនៃសេចក្តីស្រវឹង គឺសុរា និងមេរ័យ

**២ - បាតុកម្យតាចិត្តំ** គិតបំរុងនឹងផឹក ។

**៣ - តជ្ជោ វាយាមោ** ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ ។

**៤ - តស្ស បានំ** បានផឹកនូវទឹកស្រវឹងនោះឱ្យកន្លងបំពង់កចូលទៅ ។

# អង្គនៃសិក្ខាបទ ក្នុងឧបោសថសីល

- **អង្គនៃបាណាតិបាត និង អទិន្នាទាន ដូចនិច្ចសីល ខាងដើម**

- **អព្រហ្មចរិយ មានអង្គ ៤ :**

**១ - ភេទនវត្ថុ** វត្ថុជាទីទំលាយនូវសីល គឺទ្វារមគ្គទាំង ៣០ ចំពោះ ទ្វារណាមួយ ។

**២ - សេវនចិត្តំ** គិតនឹងសេព ។

**៣ - តជ្ជោ វាយាមោ** ព្យាយាមនឹងសេពនូវមេថុនធម្មនោះ ។

**៤ - មគ្គេនមគ្គប្បដិបាទនំ** ញុំាំងមគ្គនិងមគ្គឱ្យដល់គ្នា ។

- **អង្គនៃមុសាវាទ និង សុរាមេរ័យដូចនិច្ចសីលខាងដើម**

- **វិកាលភោជនៈ មានអង្គ ៣**

**១ - វិកាលោ** កាលខុស គឺព្រះអាទិត្យជ្រេទៅហើយ ដរាបទល់នឹងអរុណរះ ។

**២ _ យាវកាលិកំ** របស់ដែលគួរបរិភោគបានក្នុងកាល គឺតាំងពីអរុណរះឡើងដរាបដល់ថ្ងៃត្រង់ ។

**៣ - អជ្ឈោហរណំ** បានលេបចូលទៅក្នុងបំពង់ក ។

- **នច្ចគីតៈ ព្រមទាំងមាលា រួមគ្នាបានជាសិក្ខាបទមួយ**

**មានអង្គ ៦ :**

**១ - នច្ចគីតានិ** ការល្បែងមានរាំនិងច្រៀងជាដើម ។

**២ - កត្តុកម្យតាចិត្តំ** គិតបំរង់នឹងធ្វើ ។

**៣ - សុតទស្សនត្ថាយគមនំ** ទៅដើម្បីនេងស្តាប់ ឬមើលហើយបានស្តាប់ ឬមើល ។

**៤ - មាលានិ** វត្ថុសម្រាប់ប្រដាប់កាយ មានកម្រងជាដើម

**៥ - ធារណច្ឆន្ទតា** សេចក្តីប្រាថ្នានឹងប្រដាប់តាក់តែង ។

**៦ - តស្ស ធារណំ** បានប្រដាប់តាក់តែងនូវវត្ថុសម្រាប់ ប្រដាប់កាយ មានផ្កាកម្រងជាដើមនោះ ។

**•ឧច្ចាសយន មានអង្គ ៣ :**

**១ - ឧច្ចាសយនមហាសយនំ** ទីដេកទីអង្គុយដ៏ខ្ពស់ ដ៏ប្រសើរហួសប្រមាណ ។

**២ - បរិភោគចិត្តំ** គិតនឹងដេក ឬអង្គុយ ។

**៣ - បរិភោគករណំ** បានដេក ឬអង្គុយ ។

# កុសលកម្មបថ១០(កម្មដែលជាផ្លូវនាំទៅសុគតិ)

## I. កាយកម្ម ៣ យ៉ាង

**១ - បាណាតិបាតា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**២ - អទិន្នាទានា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬ ដោយវាចា ។

**៣ - កាមេសុ មិច្ឆាចារា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយា ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

## II. វចីកម្ម ៤ យ៉ាង

**១ - មុសាវាទា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

**២ - បិសុណាយ វាចាយ វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យញុះញង់ ស៊កសៀកបំបែកបំបាក់អ្នកដទៃ ។

**៣ - ផរុសាយ វាចាយ វេរមណី** ចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យអាក្រក់ មានពាក្យ ទ្រគោះបោះបោក ជេរប្រទេច អ្នកដទៃជាដើម ។

**៤ - សម្ផប្បលាបា វេរមណី** ចេតនាជាហេតុវៀរចាក កិរិយាពោលនូវពោលពាក្យរោយរាយ ឥតប្រយោជន៍ ។

## III. មនោកម្ម ៣ យ៉ាង

**១ - អភិជ្ឈា** មិនមានចិត្តគិតសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នក ដទៃ ដោយគិតបំរុងនឹងឱ្យបានមកជាទ្រព្យរបស់ខ្លួន ។

**២ - ព្យាបាទោ** មិនមានចិត្តចងគំនុំគុំគួន គិតប៉ងនឹងឱ្យអ្នក ដទៃដល់នូវសេចក្តីវិនាស ។

**៣ - សម្មាទិដ្ឋិ** គំនិតយល់ឃើញត្រូវ ហើយប្រកាន់ឡើង ថាត្រូវមែន ។

អ្នកណាបានប្រព្រឹត្តធម៌ត្រូវតាមកុសលកម្មបថទាំង ១០ ប្រការ ដូចបានពោលមកហើយនេះ អ្នកនោះនឹងមានសេចក្តី សេចក្តី ចម្រើនក្នុងលោកទាំងពីរ គឺក្នុងមនុស្សលោក ១ និងបរលោក ១

# អកុសលកម្មបថ១០(កម្មដែលជាផ្លូវនាំទៅអបាយភូមិ)

## I. កាយកម្ម ៣ យ៉ាង

**១ - បាណាតិបាតា** កិរិយាសម្លាប់សត្វដោយកាយរបស់ខ្លួន ឬ ប្រើគេឱ្យសម្លាប់ដោយវាចា ។

**២ - អទិន្នាទានំ** កិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬ ដោយវាចា ឬក៏ប្រើអ្នកដទៃឱ្យលួចដោយវាចា

**៣ - កាមេសុ មិច្ឆាចារា** កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ

## II. វចីកម្ម ៤ យ៉ាង

**១ - មុសាវាទោ** កិរិយាពោលនូវពាក្យកុហក ។

**២ - បិសុណាវាចា** កិរិយាពោលនូវពាក្យញុះញង់ស៊កសៀកបំបែកបំបាក់អ្នកដ៏ទៃ ។

**៣ - ផរុសវាចា** កិរិយាពោលនូវពាក្យអាក្រក់មានពាក្យ ទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម ។

**៤ - សម្ផប្បលាបោ** កិរិយាពោលនូវពោលពាក្យរោយរាយ ឥតប្រយោជន៍ ។

## III. មនោកម្ម ៣ យ៉ាង

**១ - អភិជ្ឈា** ចិត្តសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបំបំរុងនឹងឱ្យបានមកជាទ្រព្យខ្លួន ។

**២ - ព្យាបាទោ** ចិត្តចង់គំនុំគុំគួន គិតប៉ងនឹងឱ្យអ្នកដទៃដល់នូវសេចក្តីវិនាស ។

**៣ - មិច្ឆាទិដ្ឋិ** គំនិតយល់ខុស ហើយប្រកាន់ឡើងថា ខ្លួនត្រូវ ។

# អង្គនៃអកុសលកម្មបទ

**អង្គនៃបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆារ និង មុសាវាទ ដូចបានពោលមកក្នុងនិច្ចសីលខាងដើមហើយ ។**

- **បិសុណាវាចា មានអង្គ ៤**

**១ - ភិន្ទិតព្វោ បរោ** អ្នកដទៃដែលមានរូបគឺខ្លួន គប្បីញុះញង់បំបែក ។

**២ - ភេទនបុរេក្ខារតា** គិតនឹងញុះញង់បំបែកអ្នកដទៃនោះ ។

**៣ - តជ្ជោ វាយាមោ** ព្យាយាមនឹងញុះញង់បំបែកបំបាក់អ្នកដទៃ

**៤ - តស្ស តទត្ថវិជាននំ** ញុំាអ្នកនោះឱ្យដឹងច្បាស់នូវដំណើរដែលខ្លួនញុះញង់បំបែកបំបាក់នោះ ។

- **ផរុសវាចា មានអង្គ ៣**

**១ - អក្កោសិតព្វោ បរោ** អ្នកដទៃដែលមានរូបគឺខ្លួន គប្បី ជេរប្រទិច ។

**២ - កុប្បិតចិត្តំ** ចិត្តខឹងរន្ធត់ ។

**៣ - អក្កោសនា** បានជេរប្រទិចគេ ។

- **សម្ផប្បលាបៈ មានអង្គ ២**

**១ - ភារតយុទ្ធសិតាហរណាទិនិរត្ថកថា** ពាក្យឥតប្រយោជន៍ មានរឿងចម្បាំងនៃមហាភារតៈ និងរឿងរាពណ៍ លួចនាំនាងសិតាយកទៅជាដើម ។

**២ - តថារូបីកថាកថនំ** បានពោលនូវពាក្យឥតប្រយោជន៍ មានសភាពដូច្នេះ ។

- **អភិជ្ឈា មានអង្គ ២**

**១ _ បរភណ្ឌំ** ទ្រព្យជារបស់អ្នកដទៃ ។

**២ - អត្តនោ បរិណាមនំ** គិតចង់បង្អោលទ្រព្យរបស់អ្នកដទៃនោះឱ្យ បានមកជាទ្រព្យរបស់ខ្លួន ដោយកលឧបាយផ្សេង ។

- **ព្យាបាទ មានអង្គ ២**

**១ - បរសត្តោ** អ្នកដទៃក្រៅពីខ្លួន ។

**២ - តស្ស តំតំ វិនាសចិន្តា** គិតគុំគួនប្រុងនឹងឱ្យអ្នកនោះ ដល់នូវសេចក្តីវិនាស ដោយហេតុនោះៗ ។

- **មិច្ឆាទិដ្ឋិ មានអង្គ ២**

**១ - វត្ថុនោ ច គហិតាការវិបរិតតា** ចិត្តប្រែប្រួល ដោយអាការខុសអំពីព្រះរតនត្រ័យ ជាដើម ។

**២ - យថា ច នំ គណ្ហាតិ តថាភាវេន តស្សូបដ្ឋានំ** គំនិតដែលយល់ខុសពីនោះ ឃើញខុសយ៉ាងណា ក៏ប្រកាន់សេចក្តីខុសនោះ ថាត្រូវវិញ ។

អកុសលកម្មបថទាំង ១០ ប្រការ ដូចបានពោលមកហើយនេះ ទោះត្រង់បទណាក្តី លុះតែប្រកបព្រមដោយអង្គនោះៗ ទើបត្រូវទោសដល់អ្នកដែលប្រព្រឹត្តខុស អ្នកនោះនឹងដល់នូវសេចក្តីទុក្ខសេចក្តីវិនាស ក្នុងលោកនេះ និងបរលោកនាយ បើទុកជាមិនទាន់ឱ្យផលឃើញច្បាស់ ក្នុងលោកនេះ លុះដល់ទៅបរលោកនាយ ក៏គង់នឹងឱ្យផលដល់អ្នកនោះ ពុំខានឡើយ, តែបើមិនទាន់ប្រកបព្រមដោយអង្គនោះៗ គឺថា បើនៅខ្វះអង្គណាមួយនោះ ក៏មិនទាន់បាន

ឈ្មោះថា មានទោសក្នុងអកុសលកម្មបថ ដល់អ្នកដែលប្រព្រឹត្តខុសនោះឡើយ ។

អកុសលកម្មបថ ១០ ប្រការព្រមទាំងអង្គ

**ចប់ដោយសង្ខេបតែប៉ុណ្ណោះ**

ដៃ និង ជើងរបស់បុគ្គលណាទ្រុឌទ្រោមទៅ
ព្រោះជរា ថាមិនស្តាប់ ប្រាប់មិនតាម
បុគ្គលនោះមានកម្លាំងដែលត្រូវជរាកម្ចាត់ហើយ
និងប្រព្រឹត្តធម៌ដូចម្តេចបាន ។

# បរិត្តភាសនាយាចនគាថា

ពាក្យអារាធនាព្រះសង្ឃ ចម្រើនព្រះបរិត្ត

**វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា**
**សព្វទុក្ខវិនាសាយ បរិត្តំ ព្រូថ មង្គលំ ។**
**វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា**
**សព្វភយវិនាសាយ បរិត្តំ ព្រូថ មង្គលំ ។**
**វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា**
**សព្វរោគវិនាសាយ បរិត្តំ ព្រូថ មង្គលំ ។**

សូមព្រះករុណាទាំងឡាយ ចម្រើននូវព្រះបរិត្ត ជាជយមង្គល ដើម្បីនឹងការពារបញ្ចៀសនូវវិបត្តិ គឺសេចក្តីអន្តរាយទាំងពួង ដើម្បីនឹងឱ្យបានស្រេចនូវសម្បត្តិគ្រប់យ៉ាង ដើម្បីនឹងញ៉ាំងទុក្ខ ញ៉ាំងភ័យ ញ៉ាំងរោគទាំងអស់ ឱ្យវិនាសបាត់ទៅ ។

# ធម្មគារវៈ ការគោរពព្រះធម៌

ក្នុងពេលស្តាប់ព្រះធម៌ ពុទ្ធបរិស័ទត្រូវដឹងបដិបត្តិក្នុងការគោរពព្រះធម៌នោះ គឺ ព្រះអង្គទ្រង់បញ្ញត្តមិនឱ្យភិក្ខុសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ មានឆត្រនៅក្នុងដៃ មានដំបងនៅក្នុងដៃ មានគ្រឿងសស្ត្រា

នៅក្នុងដៃ មានគ្រឿងអាវុធនៅក្នុងដៃ ពាក់ទ្រនាប់ជើង ពាក់ស្បែកជើង នៅលើយាន នៅលើដំណេក អង្គុយត្របោមក្បាលជង្គង់ ជូតក្បាល ទទូរក្បាល ។

(សម្បីភិក្ខុ) អង្គុយផ្ទាល់នឹងផែនដី ហើយសម្តែងធមិដល់មនុស្សគ្មានជម្ងឺ អង្គុយនៅលើអាសនៈ, អង្គុយលើអាសនទាបហើយសម្តែងធមិដល់មនុស្សគ្មានជម្ងឺ អង្គុយលើអាសនៈខ្ពស់, ឈរសម្តែងធមិដល់មនុស្សគ្មានជម្ងឺអង្គុយ ដើរខាងក្រោយ សម្តែងធមិដល់មនុស្សគ្មានជម្ងឺដើរមុខ ។ល។ ក៏ទ្រង់ហាម ។ ទាំងអស់នេះ បើភិក្ខុណាសម្តែង ត្រូវអាបត្តិទុក្កដ ។

ព្រោះហេតុនោះ ពុទ្ធបរិស័ទត្រូវដឹងនូវសិក្ខាបទទាំងឡាយនេះ ហើយមិនត្រូវធ្វើក្នុងចំណុចណាមួយដែលព្រះអង្គហាម ដើម្បីមិនឱ្យភិក្ខុត្រូវអាបត្តិផង ដើម្បីសម្តែងនូវការគោរពក្នុងព្រះធមិផង ។

**ក្នុងអដ្ឋកថាវិន័យ គម្ពីរបរិវារៈ** សម្តែងអំពីការមិនគោរពក្នុងព្រះធមិនោះថា ចំណែកអ្នកណាអាចពិត តែមិនទៅកាន់ទីស្តាប់ធមិ មិនសូធ្យសរភញ្ញ មិនពោលធម្មកថា បំផ្លាញរោងធម្មស្សវនៈ ហើយទៅ, មានចិត្តរវើរវាយ ឬ មិនអើពើអង្គុយនៅ, មិនស្តាប់ដោយគោរព

គិតតែ ដេកលក់ ឬ ក៏អង្គុយនិយាយគ្នាលេង មិនរៀន មិនចាំទុក មិនប្រាប់ដោយគោរព គប្បីជ្រាបថា អ្នកនោះមិនគោរពក្នុងព្រះធម៌ ។

ការមិនគោរពក្នុងព្រះធម៌ជាហេតុនាំឱ្យមានទោសច្រើន នាំឱ្យវិនាសនូវប្រយោជន៍ មិនបាននូវបញ្ញាត្រាស់ដឹងសច្ចធម៌ ។ ព្រោះហេតុនោះ គួរតាំងចិត្តគោរពក្នុងព្រះធម៌ ដើម្បីបាននូវប្រយោជន៍ បាននូវបញ្ញា ដូចព្រះមានព្រះភាគ ត្រាស់ថា :

**សទ្ទហានោ អរហតំ ធម្មំ និព្វាន បត្តិយា**

**សុស្សូសំ លភតេ បញ្ញំ អប្បមត្តោ វិចក្ខណោ ។**

បុគ្គលជឿធម៌របស់ព្រះអរហន្ត ស្តាប់ដោយគោរព ជាអ្នកមិនប្រមាទ មានបញ្ញាពិចារណា រមែងបាននូវប្រាជ្ញា ដើម្បីដល់ព្រះនិព្វាន ។

# កំណាព្យសរសើគុណព្រះធម៌

អ្នកដែលជឿធម៌ព្រះអរហន្តហើយ ធម៌នាំដល់ត្រើយគឺព្រះនិព្វាន

ទាំងមិនប្រមាទឱ្យខាតសីលទាន ធ្វើអ្វីក៏មានការពិចារណា

ជាអ្នកស្តាប់ធម៌គោរពដោយល្អ មិនធ្វើមាត់ ក មិនពោលចរចា

មិនធ្វើរំខានពេលស្តាប់ទេសនា តែងបានបញ្ញាភ្លឺថ្លាដោយពិត
សូមពុទ្ធបរិស័ទអ្នកស្តាត់រកធម៌ ប្រុងស្តាប់ដោយល្អយកជាគំនិត
ទុកជាមេរៀនសម្រាប់ជីវិត កុំឱ្យងងឹតរហូតមរណា ។

(ដោយឧបាសក គុយ សុធន)

## អង្គរបស់អ្នកសូធ្យ និងអ្នកស្តាប់ ព្រះបរិត្ត

ព្រះបរិត្តនឹងមានអានុភាពច្រើន កាលអ្នកសូធ្យព្រះបរិត្ត ដល់ព្រមដោយអង្គ ៤ គឺ

**១ - បទព្យញ្ជនានិ អហាបេត្វា បរិបុណ្ណំ ឧគ្គហិតា** មិនឱ្យបទនិងព្យញ្ជនសាបសូន្យ ហើយរៀនដោយបរបូណ៌ ( មិនពោលខុសអត្ថខ្លះ បាលីខ្លះ ) ។

**២ - សព្វសោ បគុណំ កត្វា ភណន្តស្សេវ** ធ្វើឱ្យស្ទាត់ជំនាញដោយប្រការទាំងពួង ហើយពោលពិតប្រាកដ ។

**៣ - ន លាភហេតុ ឧគ្គហេត្វា** មិនរៀនព្រោះលាភជាហេតុ ។

**៤ - និស្សរណបក្ខេ ឋត្វា មេត្តំ បុរេចារិកំ កត្វា** តាំងនូវក្នុងចំណែកនៃការចេញចាកទុក្ខ ហើយធ្វើមេត្តាឱ្យប្រព្រឹត្តទៅក្នុងខាងមុខ ។ អដ្ឋកថា ។

## សូម្បីអ្នកស្តាប់ព្រះបរិត្ត ក៏ត្រូវមានអង្គ ៣ គឺ

១ - មិនធ្លាប់ធ្វើអនន្តរិយកម្ម ៥

២ - មិនមានមច្ឆាទិដ្ឋិយល់ឃើញខុសថា កម្មនិងផលកម្មមិនមាន

៣ - ជឿជាក់អានុភាពព្រះបរិត្តថា មានពិត អាចគ្រប់គ្រងរក្សាអ្នកស្តាប់បាន ។ ( មិលិន្ទបញ្ហា ) ។

# អាជីវៈនៃឧបាសក ឧបាសិកា

កិរិយាលះបង់នូវជំនួញខុស ៥ ប្រការ ហើយប្រកបកិច្ចការចិញ្ចឹម ជីវិតដោយត្រឹមត្រូវតាមធម៌ ឈ្មោះថា **អាជីវនៃឧបាសក**

ដូចមានពុទ្ធប្បញ្ញត្តិ ដែលព្រះសម្មសម្ពុទ្ធទ្រង់ហាមចំពោះភិក្ខុទាំងឡាយថា : **បញ្ចិមា ភិក្ខវេ វណិជ្ជា ឧបាសកេន អករណីយា**

ម្នាលភិក្ខុទាំងឡាយ ជំនួញខុសទាំងឡាយ ៥ ប្រការឧបាសកមិនគប្បីធ្វើឡើយ ។

- **ជំនួញខុស ៥ ប្រការនោះគឺ**

**១ - សត្ថវណិជ្ជា** ជំនួញគ្រឿងសស្ត្រាវុធសម្រាប់ប្រហារ គឺ ធ្វើគ្រឿងសស្ត្រាវុធនោះដោយខ្លួនឯង ឬឱ្យអ្នកដទៃគេធ្វើឱ្យ ហើយលក់នូវគ្រឿងសស្ត្រាវុធនោះ ។

**២ - សត្តវណិជ្ជា** ជួញដូរមនុស្ស ។

**៣ - មំសវណិជ្ជា** ជួញសាច់ គឺ ចិញ្ចឹមនូវសត្វទាំងឡាយ មានគោជាដើម លុះដល់សត្វទាំងឡាយនោះចិញ្ចឹមធំឡើង ក៏សម្លាប់យកសាច់លក់ ។

**៤ - មជ្ជវណិជ្ជា** ជួញទឹកស្រវឹង គឺផ្សំគ្រឿងស្រវឹងឯណាមួយ ឱ្យកើតឡើងជាទឹកស្រវឹងដោយខ្លួនឯង ឬទិញគេយកមក ហើយលក់នូវទឹកស្រវឹងនោះ ។

**៥ - វិសវណិជ្ជា** ជួញថ្នាំពិស គឺចាត់ចែងផ្សំថ្នាំពិស ឱ្យកើតឡើងដោយខ្លួនឯង ឬឱ្យគេផ្សំឱ្យ ឬបានមកដោយហេតុឯណាមួយ ហើយលក់នូវថ្នាំពិសនោះ ។

ឧបាសកកាលបើវៀរចាកជំនួញខុសទាំង ៥ ប្រការនេះហើយ ប្រតិបត្តិការចិញ្ចឹមជីវិតដោយធម៌ ឈ្មោះថា មានអាជីវៈធម៌ដោយប្រពៃ

# វិបត្តិនៃឧបាសក ឧបាសិកា

ធម្មជាតិដែលញ៉ាំងសីល និង អាជីវៈធម៌នៃឧបាសកឱ្យវិនាស ឈ្មោះថា **វិបត្តិ** ។

- **វិបត្តិនេះមាន ៥ យ៉ាង**

**១ - អសទ្ធោ ហោតិ** ឧបាសកមិនជឿគុណព្រះរតនត្រ័យ ។

**២ - ទុស្សីលោ ហោតិ** ឧបាសកទ្រុស្តសីល ។

**៣ - កោតុហលមង្គលិកោ ហោតិ** ឧបាសកប្រកបដោយមង្គលភ្ញាក់ផ្អើល ។

**៤ - មង្គលំ បច្ចេតិ នោ កម្មំ** ឧបាសកប្រកាន់ជឿថាមង្គលមានឫក្សពារវេលាជាដើមឱ្យផល មិនប្រកាន់ជឿថាកម្មជាកុសល និងអកុសលឱ្យផលឡើយ ។

**៥ - ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ច បុព្វការំ ករោតិ** ឧបាសកស្វែងរកតែទក្ខិណេយ្យបុគ្គល គឺបដិគ្គាហកៈអ្នកទទួលទានខាងក្រោយព្រះពុទ្ធសាសនា ហើយធ្វើនូវទាន ដល់ទក្ខិ-ណេយ្យបុគ្គលខាងក្រៅព្រះពុទ្ធសាសនានោះ ។

ឧបាសកណាមួយប្រកបដោយវិបត្តិទាំង ៥ យ៉ាងនេះ ត្រង់វិបត្តិណាមួយហើយ ឧបាសកនោះ ឈ្មោះថា **ឧបាសកចណ្ឌាល** គឺ-ឧបាសកដូចជាមនុស្សចណ្ឌាលផង ។

ឈ្មោះថា **ឧបាសកមលៈ** គឺឧបាសកមានធម៌ជាមន្ទិលសៅហ្មងផង ។

ឈ្មោះជា **ឧបាសកបដិកិដ្ឋៈ** គឺឧបាសកដែលអ្នកប្រាជ្ញទាំងឡាយលោកតិះដៀលផង ។

# សម្បត្តិនៃឧបាសក ឧបាសិកា

ធម្មជាតិដែលញ៉ាំងសីល និង អាជីវៈធម៌នៃឧបាសក ឱ្យបរិបូណ៌ ឱ្យបរិសុទ្ធប្រពៃ ឈ្មោះថា **សម្បត្តិ** ។

- **សម្បត្តិនេះមាន ៥ យ៉ាង**

**១ - សទ្ធោ ហោតិ** ឧបាសកមានសេចក្តីជឿជាក់ច្បាស់ក្នុងគុណព្រះរតនត្រ័យ ។

**២ - សីលវា ហោតិ** ឧបាសកមានសីល ។

**៣ - ន កោតុហលមង្គលិកោ ហោតិ** ឧបាសកមិនប្រកបដោយមង្គលភ្ញាក់ផ្អើល ។

**៤ - កម្មំ បច្ចេតិ នោ មង្គលំ** ឧបាសកប្រកាន់ជឿថាកម្មជាកុសល និង អកុសលឱ្យផល មិនប្រកាន់ជឿថាមង្គល មានឫក្សពារវេលាជាដើម ឱ្យផលឡើយ ។

**៥ - ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ** ឧបាសកមិនស្វែងរកទក្ខិណេយ្យបុគ្គល គឺបដិគ្គាហកៈអ្នកទទួលទានខាងក្រោយព្រះពុទ្ធសាសនាឡើយ ហើយធ្វើនូវទាន តែក្នុងទក្ខិណេយ្យបុគ្គលខាងក្នុងព្រះពុទ្ធសាសនានោះ ។

# គុណសម្បត្តិរបស់ឧបាសក ឧបាសិកា

ធម៌ល្អសម្រាប់ឧបាសក ឧបាសិកាប្រតិបត្តិគ្រប់រូប ដើម្បីនឹងឱ្យកើតឱ្យចម្រើននូវសម្បត្តិទាំងពួង ឈ្មោះថា **គុណ** ។

គុណនេះ ជារបស់ឧបាសក ឧបាសិកា ហៅថា **ឧបាសកគុណ**

- **មាន ១០ យ៉ាងគឺ**

**១ - សង្ឃេន សទ្ធឹ សមានសុខទុក្ខោ ហោតិ** ឧបាសកអ្នករួមសេចក្តីសុខទុក្ខ មួយអន្លើដោយភិក្ខុសង្ឃ គឺថា បើភិក្ខុសង្ឃមានសេចក្តីសុខ ក៏ត្រេកអរ បើភិក្ខុសង្ឃមានសេចក្តីទុក្ខព្រួយ ក៏ព្រួយជាមួយផង ។

**២ - កាយិកវាចសិកញ្ចិ សុរក្ខិតំ ហោតិ** ឧបាសកមានកាយកម្ម និងវចីកម្មរក្សាហើយដោយប្រពៃ ។

**៣ - ធម្មោ អធិបតេយ្យោ ហោតិ** ឧបាសកមានធម៌ជាអធិបតី គឺថា បើប្រព្រឹត្តធ្វើអ្វីៗ រមែងកាន់យកធម៌ជាធំ ជាទីតាំងជាទីអាងមាំ មិនឱ្យខុស មិនឱ្យឃ្លៀងឃ្លាតអំពីធម៌ឡើយ ។

**៤ - យថាថាមេន សំវិភាគគោ ច ហោតិ** ឧបាសកជាអ្នកត្រេកអរក្នុងការបរិច្ចាគទាន តាមសមគួរដល់កម្លាំងនៃខ្លួន គឺធ្វើទាន

តាមសមគួរដល់ទ្រព្យតិចនិងច្រើន បើមានតិចក៏ធ្វើតិច បើមានច្រើនក៏ធ្វើច្រើន មិនមានមច្ឆរិយៈធម៌គ្រប់សង្កត់សន្តានចិត្តឡើយ ។

**៥ - ជិនសាសនំ ជានិតុញ្ច វាយមតិ** ឧបាសកឧស្សាហ៍ព្យាយាម ដើម្បីនឹងឱ្យដឹងច្បាស់នូវសាសនៈ គឺពាក្យប្រៀនប្រដៅពាក្យបណ្តាំនៃព្រះជិនស្រី ។

**៦ - សម្មាទិដ្ឋិកោ វ ហោតិ** ឧបាសកជាសម្មាទិដ្ឋិ គឺមានប្រាជ្ញាឃើញត្រូវតាមសេចក្តីពិត ។

**៧ - អបគតោ កោតុហលមង្គលិកោ វ ហោតិ** ឧបាសកប្រាសចាកមង្គលភ្ញាក់ផ្អើល ហើយជាអ្នកមិនប្រកាន់ជឿថា មង្គលមានឫក្សពារ វេលាជាដើមឱ្យផលឡើយ ប្រកាន់ជឿតែកម្មជាកុសលនិងអកុសលថាឱ្យផល ។

**៨ - ជីវិតហេតុបិ អញ្ញំ សត្ថារំ ន ឧទ្ទិសតិ** ឧបាសកបើទុកជាមានហេតុគួរដល់សេចក្តីវិនាសជីវិតក្តី ក៏មិនលះបង់ព្រះរតនត្រ័យហើយត្រឡប់ទៅកាន់យកមនុស្សដទៃ ជាគ្រូអាចារ្យជាទីពឹងរបស់ខ្លួនថាប្រសើរជាងព្រះរតនត្រ័យនោះឡើយ ។

**៩ - សមគ្គារាមោ វ ហោតិ** ឧបាសកមានសេចក្ដីត្រេកអរក្នុងសាមគ្គីធម៌ គឺសេចក្ដីព្រមព្រៀងគ្នា ។

**១០ - សាសនេ ចរតិ** ឧបាសកប្រព្រឹត្តល្អក្នុងព្រះពុទ្ធសាសនា គឺប្រព្រឹត្តតាមតែធម៌វិន័យជាពុទ្ធសាសនា ។

**សុខំ យាវ ជរា សីលំ សុខា សទ្ធា បតិដ្ឋិតា**

**សុខោ បញ្ញាបដិលាភោ បាបានំ អករណំ សុខំ ។**

**សីល** នាំសេចក្ដីសុខមកឲ្យ ដរាបដល់ចាស់ជរា

**សទ្ធា** ដែលបុគ្គលតាំងចុះស៊ប់មាំហើយ នាំសេចក្ដីសុខមកឲ្យ

**ការបាននូវបញ្ញា** នាំមកនូវសេចក្ដីសុខ

**ការមិនធ្វើបាបទាំងឡាយ** នាំមកនូវសេចក្ដីសុខ ។

**គាថាធម្មបទ**

# សាច់ជាអកប្បិយៈមិនគួរប្រគេន

**១ - មនុស្សមំសំ** សាច់មនុស្ស

**២ - ហត្ថិមំសំ** សាច់ដំរី

**៣ - អស្សមំសំ** សាច់សេះ

**៤ - សុនខមំសំ** សាច់ឆ្កែ

**៥ - អហិមំសំ** សាច់ពស់

**៦ - សីហមំសំ** សាច់សីហៈ

**៧ - ព្យគ្ឃមំសំ** សាច់ខ្លាធំ

**៨ - ទីបិមំសំ** សាច់ខ្លាដំបង

**៩ - អច្ឆមំសំ** សាច់ខ្លាឃ្មុំ

**១០ - តរច្ឆមំសំ** សាចខ្លារខិន ។

( វិនយបិដក ភាគ ៧ ទំព័រ ២៧៩ - ២៨៤ )

# អដ្ឋកថា

បទថា **បវត្តមំសំ** បានដល់ សាច់របស់សត្វដែលស្លាប់ហើយនោះឯង ដែលគេដាក់លក់តាមផ្សារជាដើម ។

បទថា **អប្បដិវេក្ខិត្វា** បានដល់ អប្បដិបុច្ឆិត្វា ប្រែថា មិនសាកសួរជាមុន ។ ក៏បើភិក្ខុដឹងថា នេះសាច់ប្រភេទនោះ ។ កិច្ចដែលត្រូវសាកសួរ រមែងមិនមាន, តែកាលបើមិនដឹង ត្រូវសួរជាមុនសិនសឹមឆាន់ ។

វិនិច្ឆ័យក្នុងពាក្យថា **សុនខមំសំ** ( សាច់ឆ្កែ ) នេះ បណ្ឌិតគប្បីជ្រាបថា ឆ្កែព្រៃ រមែងដូចឆ្កែស្រុកដែល, សាច់ឆ្កែព្រៃនោះគួរ ។ ចំណែកឆ្កែណា កើតដោយមេឆ្កែស្រុក និងឆ្កែព្រៃរួមសំវាសគ្នា ឬដោយមេឆ្កែព្រៃ និងឆ្កែស្រុករួមសំវាសគ្នា សាច់របស់កូនឆ្កែនោះមិនគួរ ។ ព្រោះថា ឆ្កែនោះគប់រកគ្នាទាំងពីរចំណែក ។

សាច់ក្តី ឆ្អឹងក្តី ឈាមក្តី ស្បែកក្តី រោមក្តី នៃសត្វទាំង ១០ ប្រភេទ មានមនុស្សជាដើមទាំងនេះ មិនគួរទាំងអស់ ដោយប្រការដូច្នេះ,។ កាលភិក្ខុដឹងក៏ដោយ មិនដឹងក៏ដោយ ឆាន់សាច់ណាមួយគង់ជាអាបត្តិពិត ។ ដឹងពេលណាគប្បីសម្តែងអាបត្តិពេលនោះ ។

# សាច់បរិសុទ្ធ ៣ យ៉ាង

**ន ភិក្ខវេ ជានំ ឧទ្ទិស្ស កតំ មំសំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ**

**អាបត្តិ ទុក្កដស្ស ។** ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដឹងថាសាច់គេធ្វើចំពោះ (ខ្លួន) កុំគប្បីបរិភោគ ភិក្ខុណាបរិភោគត្រូវអាបត្តិទុក្កដ ។

**អនុជានាមិ ភិក្ខវេ តិកោដិបរិសុទ្ធំ មច្ឆមំសំ អទិដ្ឋំ អស្សុតំ អបរិសង្កិតំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតត្រី និងសាច់ដែលបរិសុទ្ធដោយបំផុត ៣ យ៉ាង គឺមិនបានឃើញ មិនបានឮ មិនបានរង្កៀស ។ ( វិនយបិដក ភាគ ៧ / ៣៣៧ )

# ការប្រគេនព្រះសង្ឃដែលត្រឹមត្រូវ

ទាយកទាយិកាអ្នកថ្វាយទាន គប្បីជាអ្នកឈ្លាសក្នុងកិច្ចនៃការប្រគេនចង្ហាន់ (បុណ្យប្រកបដោយបញ្ញា) បើប្រគេនមិនត្រឹមត្រូវតាមព្រះវិន័យទេ ភិក្ខុមិនអាចឆាន់នូវរបស់នោះបានឡើយ ព្រោះព្រះសម្មាសម្ពុទ្ធ ទ្រង់បានកំណត់ការទទួលប្រគេនដែលប្រកបដោយអង្គ ៥ ទើបអាចឆាន់បាន មិនមានទោស ។

- **អង្គនៃការប្រគេន ៥ យ៉ាងគឺ**

**(សមន្ត.ភាគ៤/ទំ.២៤៦)**

**១ - ថាមមជ្ឈិមស្ស បុរិសស្ស ឧច្ចារណមត្តំ ហោតិ** វត្ថុដែលបុរសមានកម្លាំងយ៉ាងកណ្តាលល្មមលើកឡើងបាន

**២ - ហត្ថបាសោ បញ្ញាយតិ** ហត្ថបាសប្រាកដ (ទាយកចូលមកនៅក្នុហត្ថបាស)

**៣ - អភិហារោ បញ្ញាយតិ** បង្អោនចូលមកប្រគេន

**៤ - ទេវោ វា មនុស្សោ វា តិរច្ឆានគតោ វា កាយេន វា កាយបដិពន្ធេន វា និស្សគ្គិយេន វា ទេតិ** ទេវតាក្តី មនុស្សក្តី សត្វតិរច្ឆានក្តីប្រគេនដោយកាយ ឬដោយវត្ថុជាប់កាយ ឬដោយការបោះឱ្យ ។

**៥ - តំ បន ភិក្ខុ កាយេន វា កាយបដិពន្ធេន វា បដិគ្គណ្ហាតិ** ចំណែកភិក្ខុវិញទទួលវត្ថុនោះ ដោយកាយក្តី ឬដោយវត្ថុជាប់កាយក្តី ។

## • អធិប្បាយអង្គនីមួយៗ

**អង្គទី ១** : សំដៅយករបស់ដែលត្រូវប្រគេននោះ ជារបស់ដែលមជ្ឈិមបុរស គឺបុរសមានវ័យកណ្តាល អាចលើករួច ។

បើរបស់នោះមជ្ឈិមបុរសលើករួច តែតាយាយចាស់ៗ មានកម្លាំងខ្សោយលើកម្នាក់ឯងមិនរួច ជួយគ្នាសែងរបស់នោះពីរ ឬបីនាក់ យកមកប្រគេន ក៏គួរដែរ ។

ពាក្យថាសែងយកមកប្រគេននេះ យកខ្នាតដែលមជ្ឈិមបុរសលើករួច បើមជ្ឈិមបុរសលើកម្នាក់ឯងមិនរួចទេ ហើយនាំគ្នាសែងយកមកប្រគេន ឈ្មោះថា មិនត្រឹមត្រូវទេ ។

**អង្គទី២** : ប្រគេនត្រូវប្រកបដោយហត្ថបាសគឺ ២ហត្ថ ១ចំអាម បើភិក្ខុអង្គុយ គិតត្រឹមអវយវៈខាងក្រោយចូលមក ឯអ្នកប្រគេន គិតយកអវយវៈដែលនៅជិតជាងគេ វៀរលែងតែដៃដែលលាចេញមក ។ បើភិក្ខុឈរ ដូចជា លោកនិមន្តបិណ្ឌបាតជាដើម គិតត្រឹមកែងជើងលោកចូលមក ឯអ្នកប្រគេន គិតយកអវយវៈដែលនៅជិតជាងគេ វៀរលែងតែដៃដែលលាមកប្រគេន ។ គួរកំណត់លែលកមើលប្រមាណឱ្យល្មមចុះ សូមជ្រាបថា ហត្ថបាសនៃការប្រគេននេះ បើខ្វះតែ ១ចម្រៀកសក់ ក៏ឈ្មោះថា មិនត្រឹមត្រូវទៅតាមអង្គនៃការប្រគេន ២ហត្ថ ១ចំអាម ។

**អង្គទី ៣** : បង្អោនចូលមកប្រគេន, ពាក្យថា បង្អោនមកប្រគេននេះ, អ្នកប្រគេនលើលឡើងក្ដី រុញក្ដី ផ្អៀងក្ដី បង្ខិតក្ដី នូវរបស់នោះឱ្យកម្រើក ឬឱ្យឃ្លាតចាកទី ឈ្មោះថា បង្អោនទាំងអស់ ។

មួយទៀតទាយកទាយិកា បានរៀបចំចង្ហាន់ដាក់លើតុ ឬក៏ លើថាស លុះពេលដែលត្រូវប្រគេន បើគ្រាន់តែចាប់កាន់តុ ឬក៏ ចាប់កាន់ថាស មិនលើកឡើង មិនបង្អិត ឱ្យឃ្លាតចាកទី ឈ្មោះថាមិនបានបង្អោន ប្រគេនទេ លុះត្រាអ្នកប្រគេននោះបានលើកឡើង ឬបង្អិតនូវរបស់ នោះឱ្យឃ្លាតចាកទី ទើបឈ្មោះថា បង្អោនចូលប្រគេន ។

**អង្គទី៤** : សំដៅយកអ្នកប្រគេនជាមនុស្សក្តី ជាទេវតាក្តី ដោយ ហោយទៅសូម្បីជាសត្វតិរច្ឆានក៏បាន ។ ដូចកាលព្រះអង្គគង់នៅព្រៃបា លិល័យជាដើម សត្វដំរី សត្វស្វា ជាអ្នកគាល់បម្រើព្រះអង្គ ជាអ្នក ប្រគេននូវចង្ហាន់ផ្លែឈើដល់ព្រះអង្គសោយ ។ បទថា **ដោយការបោះ ឱ្យ** មានសេចក្តីថា ក៏របស់ដែលគេប្រគេនដោយបោះ ឱ្យផុតពីកាយ និងរបស់ជាប់ដោយកាយ ដល់ភិក្ខុដែលនៅក្នុងហត្ថបាសដោយកាយ ឬដោយរបស់ជាប់ដោយកាយ ឈ្មោះថា គេប្រគេនដោយប្រយោគ ដែលបោះឱ្យ ។

**អង្គទី ៥ : ដោយកាយ** គឺ គេឱ្យដោយអវយវៈណាមួយ មានដៃ ជាដើម ដោយហោចទៅ សូម្បីដោយម្រៀមជើង ក៏ឈ្មោះថា គេឱ្យ ហើយដោយកាយ ។ សូម្បីក្នុងការទទួលប្រគេន ក៏ន័យនេះឯង ។

ពិតមែន របស់ដែលភិក្ខុទទួលប្រគេនដោយអវយវៈ (ចំណែកនៃរាងកាយ) ណាមួយ ចាត់ថា ទទួលប្រគេនហើយដោយកាយដូចគ្នា ។

បទថា **ដោយរបស់ដែលជាប់កាយ** មានសេចក្តីថា របស់ដែលគេប្រគេនដោយឧបករណ៍យ៉ាងណាមួយ មានវែកជាដើម ឈ្មោះថាប្រគេនដោយរបស់ជាប់ដោយកាយ ។ សូម្បីក្នុងការទទួលប្រគេន ក៏ន័យនេះដូចគ្នា ។ របស់ដែលភិក្ខុទទួលដោយវត្ថុណាមួយដែលជាប់ដោយរាងកាយ មានបាត្រនិងថាសជាដើម ចាត់ថា ទទួលប្រគេនដោយរបស់ជាប់ដោយកាយ ដូចគ្នា។

## ការដាច់ប្រគេន មានដោយហេតុ ៧យ៉ាង គឺ

**១ - លិង្គបរិវត្តេន** ដោយការត្រឡប់ភេទ (គឺភិក្ខុទៅជាភិក្ខុនី )

**២ - កាលកិរិយាយ** ដោយការធ្វើមរណកាល

**៣ - សិក្ខាបច្ចក្ខានេន** ដោយការពោលលាសិក្ខា

**៤ - ហីនាយាវត្តនេន** ដោយការវិលទៅរកភេទដ៏ថោកទាប

**៥ - អនុបសម្បន្នស្ស ទានេន** ដោយការឱ្យដល់អនុសម្បន្ន

**៦ - អច្ឆិន្ទិត្វា គាហេន** ដោយការដែលចោរលួចយកទៅ

**៧ - អនបេក្ខវិស្សជ្ជនេន** ដោយការលះបង់មិនស្តាយ

## • សេចក្តីអធិប្បាយ

**មែនពិតចង្ហាន់ដែលភិក្ខុ១អង្គទទួលហើយ ភិក្ខុទាំងឡាយរមែងអាចឆាន់បាន ដោយមិនចាំបាច់ប្រគេនថ្មីទេ វៀរលែងតែដាច់ប្រគេនហើយ ទើបត្រូវប្រគេនសាជាថ្មី**

**ហេតុទី ១** : ភិក្ខុបានទទួលចង្ហាន់ហើយ ក៏ស្រាប់តែប្រែភេទទៅជាភិក្ខុនីវិញ ចង្ហាន់នោះឈ្មោះថា **ដាច់ប្រគេនហើយ** ។ នៅសម័យពុទ្ធកាល ធ្លាប់មានភិក្ខុប្រែភេទទៅជាភិក្ខុនី ព្រោះអកុសលកម្មណាមួយ ដែលខ្លួនបានធ្វើហើយ ។

**ហេតុទី ២** : ចង្ហាន់ដែលភិក្ខុបានទទួលប្រគេនហើយ តែលោកលោកធ្វើមរណៈកាលភ្លាមៗ ក្នុងពេលនោះទៅ ដោយហេតុណាមួយចង្ហាន់នោះ ឈ្មោះថា **ដាច់ប្រគេនហើយ** ។

**ហេតុទី៣** : ភិក្ខុបានទទួលចង្ហាន់ហើយ ស្រាប់តែលោកលាចាកសិក្ខាបទ គឺសឹកមកជាគ្រហស្ថ នៅក្នុងពេលនោះ ចង្ហាន់នោះឈ្មោះថា **ដាច់ប្រគេនហើយ** ។

**ហេតុទី ៤** : ចង្ហាន់ដែលភិក្ខុបានទទួលប្រគេនហើយ លោកក៏ចូលសាសនាដទៃវិញ ឬក៏ត្រូវអាបត្តិបារាជិក ដោយហេតុតែលោកមានបញ្ញាតិចតួច មិនបានពិចារណាផែងឆ្ងាយ ក៏លែងជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ចង្ហាន់នោះ ឈ្មោះថា **ដាច់ប្រគេនហើយ** ។

**ហេតុទី ៥** : ភិក្ខុទទួលចង្ហាន់ហើយ ស្រាប់តែប្រគល់ចង្ហាន់នោះ ឱ្យដល់អនុប្បសម្បន្ន គឺ បុគ្គលដែលមិនមែនជាភិក្ខុផងគ្នា ដូចជាលោកលះចង្ហាន់នោះឱ្យដល់សាមណេរ ឬឧបាសក ឧបាសិកា ណាមួយក៏ដោយ ចង្ហាន់នោះ ឈ្មោះថា **ដាច់ប្រគេនហើយ** ។

**ហេតុទី ៦** : ភិក្ខុបានទទួលចង្ហាន់ហើយ ស្រាប់តែត្រូវពួកចោរដណ្តើមយកទៅ ចង្ហាន់នោះឈ្មោះថា **ដាច់ប្រគេនហើយ** ។

**ហេតុទី ៧** : ភិក្ខុបានទទួលចង្ហាន់ហើយ ស្រាប់តែលែងចង់ឆាន់ ក៏លះបង់ចង្ហាន់នោះចោលទៅ គឺដាច់អាល័យហើយលះផុតអំពីដៃ ឈ្មោះថា **ដាច់ប្រគេនហើយ** ។

**សូមបញ្ជាក់ថា** នៅកន្លែងខ្លះ មានពុទ្ធបរិស័ទមួយចំនួនប្រគេនចង្ហាន់ព្រះសង្ឃហើយ មិនហ៊ានចាប់កាន់ ឬប៉ះពាល់ ដូចជាការជួយបង្ខិត ជួយបើកគម្រប ឬរៀបចំទុកដាក់ឱ្យបានល្អ ព្រោះខ្លាច

ដាច់ប្រគេន ។ សេចក្ដីទាំងអស់នេះ ជាការយល់ច្រឡំទាំងអស់ ។ ហេតុដទៃ ក្រៅអំពីហេតុ៧ យ៉ាង ដូចបានពោលមកខាងលើនេះ មិនមែនជាហេតុឱ្យដាច់ប្រគេននោះឡើយ ។ សូមពុទ្ធបរិស័ទទាំងឡាយគប្បីចំណាំត្រង់ចំណុចនេះផងចុះ និងបានបដិបត្តិបានត្រឹមត្រូវ ។

របស់ដែលពុទ្ធបរិស័ទមិនបានប្រគេនឱ្យត្រឹមត្រូវ ទៅតាមអង្គនៃការប្រគេនទាំង៥យ៉ាងក្ដី ឬ បានប្រគេនត្រឹមត្រូវហើយ តែត្រូវដាច់ប្រគេនវិញដោយហេតុនៃទាំង៧យ៉ាងណាមួយ របស់នោះឈ្មោះថា ជ **ជារបស់មិនបានប្រគេនទេ** បើភិក្ខុណាឆាន់ នឹងត្រូវអាបត្តិបាចិត្តយៈគ្រប់ៗមាត់ ដែលលេបកន្លងបំពង់កចូលទៅ ។

**សូមបញ្ជាក់ថា** អង្គនៃការប្រគេនទាំង៥យ៉ាងនេះ គឺ និយាយចំពោះភិក្ខុតែប៉ុណ្ណោះ មិនទូទៅដល់សាមណេរឡើយ ព្រោះសាមណេរមិនឃើញមាន វិន័យហាមប្រាមត្រង់ចំណុចនេះផងទេ ។

# ការធ្វើកប្បិយៈ (ធ្វើរបស់មិនគួរ ឱ្យគួរបរិភោគបាន)

នៅក្នុងវិនយបញ្ញត្តិ ព្រះដ៏មានព្រះភាគ ទ្រង់ហាមមិនឱ្យភិក្ខុធ្វើភូតគាម ឬពីជគាមឱ្យវិនាសទេ[១] ។ ដើមឈើតូចក៏ដោយ ធំក៏ដោយ មានស្មៅជាដើម ហៅថា **ភូតគាម** ។ របស់ដែលមានពូជអាចដុះបាន ផ្លែឈើមានគ្រាប់ ឬដើមឈើមានថ្នាំងជាដើម ដែលគេកាត់ដាច់ពីដើម ហើយ អាចដុះបាន ហៅថា **ពីជគាម** ។

## សមណកប្បៈ ៥ យ៉ាង

ពីជគាមទាំងអស់ មុននឹងឆាន់ ត្រូវធ្វើឱ្យសមគួរសិន ទើបឆាន់បាន តាមព្រះអង្គទ្រង់អនុញ្ញាតទុកថា " **អនុជានាមិ ភិក្ខវេ បញ្ចហិ សមណកប្បេហិ ផលំ បរិភុញ្ជិតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុឆាន់ផ្លែឈើដោយសមណកប្បៈ[២] **៥យ៉ាង**" ។

**១. អគ្គិបរិចិតំ** ដែលគេអុជ ឬដុតដោយកំដៅភ្លើង

---

[១] ការធ្វើភូតគាមឱ្យវិនាស ត្រូវអាបត្តិបាចិត្តិយៈចំណែកការធ្វើពីជគាមឱ្យវិនាស , ត្រូវអាបត្តិទុក្កដ ទ្រង់អនុញ្ញាតសមណកប្បៈដើម្បីឱ្យរួចចាកអាបត្តិទុក្កដ ព្រោះការធ្វើទំលាយនូវ **ពីជគាម** ។

[២] ផ្លែឈើដែលគេធ្វើឱ្យសមគួរដល់សមណៈ ។

**២. សត្ថបរិចិតំ** ដែលគេចោះ ពុះ ចិតដោយសាស្ត្រា

**៣. នខបរិចិតំ** ដែលគេចុចដោយក្រចក

**៤. អពីជំ** ដែលគ្មានពូជដុះតទៅទៀត

**៥. និព្វត្តពីជំ** មានពូជដែរ តែគួរបន្ទិចគ្រាប់ចេញបាន។

**<u>អដ្ឋកថា</u>** : បណ្ដាបទទាំងនោះ បទថា **អគ្គិបរិចិតំ** មានអត្ថថា អុជ គឺ ស្រុស ដុត អាំងហើយ ដោយភ្លើង ។

បទថា **សត្ថបរិចិតំ** មានអត្ថថា ចោះ គឺ ពុះ ចិត កាត់ ឬចាក់ហើយដោយកាំបិតតូច ។ ក្នុងពាក្យនោះ ចុចដោយក្រចកក៏ន័យនេះឯង ។ ផ្លែឈើដែលមិនមានគ្រាប់ និងផ្លែឈើដែលប្រឡេះគ្រាប់ចេញហើយ ជាកប្បិយដោយខ្លួនឯងហើយ ។

ដីកាវិមតិវិនោទនី ភាគ២ ពន្យល់ថា

សូម្បីអដ្ឋកថា ពោកថា កប្បយន្តិ វត្វាវ (កាតព្វំ) គប្បីពោលថា កប្បិយំហើយធ្វើចុះ ដីកាលោកពន្យល់ថា គប្បីធ្វើនូវដំបៅត្រង់ពីជគាម ដោយភ្លើង ឬដោយសស្ត្រាជាដើម ក្នុងខណៈនោះនៃពាក្យប៉ុណ្ណោះ តែមិនគួរធ្វើមុនពោល ដីកាពន្យល់ទៀតថា ក៏ឯគប្បីធ្វើការចាក់ ឬទម្លាយនោះ

ឯង មិនគួរធ្វើឱ្យពីរចំណែក គឺ មិនគួរធ្វើនូវការចាក់ជាដើម និងពេល មុនក្រោយ ។

**<u>វិធីនៃការធ្វើកប្បិយៈ</u>** គឺ ញាតិញោមយកផ្លែឈើមានផ្លែឪទ្បឹក ជាដើមមកប្រគេន ពេលលោកទទួលហើយត្រូវឱ្យធ្វើកប្បិយៈ ដើម្បី ឆាន់ទៅមិនត្រូវទោស ញាតិញោមត្រូវយកកាំបិតមុតស្រួច ឬក្រចកដៃ ជាដើមក៏បាន សម្រាប់ធ្វើកប្បិយៈ(ពុះ ចិត កាត់ ចាក់ ឬចុច) ពេលលោកពោលថា **កប្បិយំ ករោហិ** (ចូរធ្វើរបស់នេះឱ្យគួរ )

អ្នកដែលធ្វើកប្បិយៈ ត្រូវពុះ ចិត កាត់ ឬចាក់ ទៅលើផ្លែឪទ្បឹកជា ដើមនោះ ព្រមដោយពាក្យនិយាយថា **កប្បិយំ ភន្តេ** (គួរលោកម្ចាស់) គឺ តូវពោលពាក្យថា **កប្បិយំ ភន្តេ** (គួរលោកម្ចាស់ ) ឱ្យប្រព្រឹត្តទៅ ក្នុងខណៈដែលកាំបិត កំពុងចាក់ចូលឬកំពុងជាប់នឹងផ្លែឈើ ដែល មិនទាន់បានដកចេញនៅឡើយ ។

**<u>បញ្ជាក់</u>** ការធ្វើកប្បិយៈ ជាភាសាខ្មែរ ក៏គួរ ។

# ពាក្យវេរផ្សេង ៗ

## ១.ពាក្យវេរបិណ្ឌបាតថ្វាយព្រះសម្មាសម្ពុទ្ធ

**ឱកាស មយំ ភន្តេ ឥមានិ ភត្តានិ សសក្ការានិ សម្មាសម្ពុទ្ធស្ស ទេម,**

**សាធុ នោ ភន្តេ ភគវា ឥមានិ ភត្តានិ សសក្ការានិ**

**បដិគ្គណ្ហាតុ មាតាបិតុអាទីនញ្ច អម្ហាកញ្ច**

**ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

**ទុតិយម្បិ ............. ។**

**តតិយម្បិ ............. ។**



**ឱកាស** ខ្ញុំសូមគោរព! បពិត្រព្រះមានព្រះភាគដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ សូមបូជាថ្វាយ នូវចង្ហាន់បិណ្ឌបាត ព្រមទាំងគ្រឿងសក្ការៈទាំងឡាយនេះ ចំពោះព្រះសម្មាសម្ពុទ្ធ, បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ មេត្តាអនុគ្រោះទទួលយក នូវចង្ហាន់បិណ្ឌបាត ព្រម-ទាំងគ្រឿងសក្ការៈទាំងឡាយនេះ របស់ខ្ញុំព្រះអង្គទាំងឡាយ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

។ល។ ជាគម្រប់ពីរដងផង ។

។ល។ ជាគម្រប់បីដងផង ។

## ២.ពាក្យវេរផ្កាថ្វាយចំពោះព្រះរតនត្រ័យ

**ឱកាស មយំ ភន្តេ ឥមានិ បុប្ផានិ សសក្ការានិ សម្មាសម្ពុទ្ធស្ស ទេម, សាធុ នោ ភន្តេ ឥមានិ បុប្ផានិ សសក្ការានិ បដិគ្គណ្ហាតុ មាតាបិតុអាទីនញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**



**ទុតិយម្បិ ............. ។**

**តតិយម្បិ ............. ។**

**ឱកាស** ខ្ញុំសូមគោរព! បពិត្រព្រះមានព្រះភាគដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ សូមបូជាថ្វាយ នូវបុប្ផាផ្កាស្រស់ ព្រមទាំងគ្រឿងសក្ការៈទាំងឡាយនេះ ចំពោះព្រះសម្មាសម្ពុទ្ធ, បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ មេត្តាអនុគ្រោះទទួលយក នូវបុប្ផាផ្កាស្រស់ ព្រមទាំងគ្រឿងសក្ការៈទាំងឡាយនេះ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជា-

ដើមផង ដល់ខ្ញុំព្រះករុណាទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

៕ល៕ ជាគម្រប់ពីរដងផង ។

៕ល៕ ជាគម្រប់បីដងផង ។

## ឬទេវមួយបែបទៀត

**ឧកាស មយំ ភន្តេ ភគវា ឥមានិ សសក្ការានិ ទីបធូបបុប្ផវរានិ រតនត្តយស្ស ទេម, អម្ហាកំ ឥមស្ស រតនត្តយស្ស បូជា ទីឃរត្តំ ហិតសុខាវហា ហោតុ, អាសវក្ខយប្បត្តិយា ។**



**ទុតិយម្បិ** ...... ។

**តតិយម្បិ** ...... ។

**ឧកាស** ខ្ញុំសូមគោរព ! បពិត្រព្រះមានព្រះភាគដ៏ចម្រើន យើងខ្ញុំ-ព្រះអង្គទាំងឡាយ សូមបូជាថ្វាយ នូវទៀនធូប (ដែលជាប្រទីប) និងបុប្ផាផ្កាស្រស់ដ៏ប្រសើរ ព្រមទាំងគ្រឿងសក្ការៈទាំងឡាយនេះ ចំពោះព្រះរតនត្រ័យ, កិរិយាបូជាចំពោះព្រះរតនត្រ័យនេះ ចូរជាផលនាំមក នូវប្រយោជន៍ និងសេចក្តីសុខ ដល់យើងខ្ញុំព្រះ

អង្គទាំងឡាយ អស់កាលដ៏យូរ ចូរជាបច្ច័យដើម្បីបានដល់នូវព្រះនិព្វានជាទីអស់ទៅនៃអាសវកិលេសហោង ។

៕ល៕ ជាគម្រប់ពីរដងផង ។

៕ល៕ ជាគម្រប់បីដងផង ។

## ៣.ពាក្យវេរថ្វាយកឋិនចំពោះសង្ឃ

**ឥមំ ភន្តេ កឋិនចីវរំ សានិសង្សំ សង្ឃស្ស ទេម ។**

**ទុតិយម្បិ.... ។តតិយម្បិ.... ។**



បពិត្រព្រះសង្ឃដ៏ចម្រើន យើងខ្ញុំព្រះករុណាទាំងឡាយ សូមវេរថ្វាយនូវកឋិនចីវរនេះព្រមទាំងអានិសង្សលាភ ដល់ព្រះសង្ឃ ។

.... អស់វារៈពីរដងផង។

.... អស់វារៈបីដងផង ។

**សាធុ នោ ភន្តេ សង្ឃោ ឥមំ កឋិនចីវរំ សានិសង្សំ បដិគ្គណ្ហាតុ កឋិនំ អត្ថរិតុំ ។** បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃមេត្តាទទួលយក នូវកឋិនចីវរ ព្រមទាំងអានិសង្សលាភ របស់ខ្ញុំព្រះករុណាទាំងឡាយ ដើម្បីក្រាលកឋិន ។

**មាតាបិតុអាទីនញ្ច គុណវន្តានំ អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។** ដើម្បីបាននូវសេចក្តីចម្រើន ដើម្បីបាននូវប្រយោជន៍, ដើម្បី-បាននូវសេចក្តីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

## ៤.ពាក្យវេរសេនាសនៈថ្វាយសង្ឃ

**ឱកាស ឥមំ ភន្តេ កុដិមញ្ចបីឋាទិសេនាសនំ លោមាទិកាយេន ផុសិត្វា យថាសុខំ បរិភុញ្ជិតុំ សង្ឃស្ស ទេម, សាធុ នោ ភន្តេ ឥមំ កុដិមញ្ចបីឋាទិសេនាសនំ បដិគ្គណ្ហាតុ មាតាបិតុអាទីនញ្ច អម្ហាកញ្ច ទីឃ-រត្តំ អត្ថាយ ហិតាយ សុខាយ ។**



**ទុតិយម្បិ ..... ។**

**តតិយម្បិ ..... ។**

សូមគោរព បពិត្រព្រះសង្ឃដ៏ចម្រើន យើងខ្ញុំទាំងឡាយសូមប្រគេននូវសេនាសនៈមានកុដិ គ្រែ និង តាំងជាដើមនេះ ដល់ព្រះសង្ឃ ដើម្បីព្រះសង្ឃប្រើប្រាស់ ប៉ះពាល់ដោយកាយមាន

ធោមជាដើម តាមសប្បាយបាន, បពិត្រព្រះសង្ឃដ៏-ចម្រើន សូមព្រះសង្ឃមេត្តាអនុគ្រោះទទួលយក នូវសេនាសនៈមានកុដិ គ្រែ និង តាំងជាដើមនេះ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

ៗលៗ ....ជាគម្រប់ពីរដងផង ។

ៗលៗ ....ជាគម្រប់បីដងផង ។

## ៥.ពាក្យវេរគម្ពីរព្រះត្រៃបិដក និងអដ្ឋកថា

**ឧកាស មយំ ភន្តេ ឥមានិ តិបិដកញ្ច អដ្ឋកថាយោ ច សបរិក្ខារញ្ច ឥធានេត្វា ភិក្ខុសង្ឃស្ស ទេម, សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមានិ តិបិដកាទីនិ បដិគ្គណ្ហាតិ មាតាបិតុអាទីនញ្ច ញាតិមិត្តានញ្ច សព្វសត្តានញ្ច សបរិវារានំ អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

**ទុតិយម្បិ ..........** ។

**តតិយម្បិ ...........** ។



**ឧកាស** ខ្ញុំសូមគោរព បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើន យើងខ្ញុំទាំងឡាយ មានចិត្តជ្រះថ្លា

ណាស់ បាននាំមកនូវគម្ពីរព្រះត្រៃបិដកផង អដ្ឋកថាទាំងឡាយផង ព្រមទាំងគ្រឿងបរិក្ខារទាំងឡាយផង មកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះ-ភិក្ខុសង្ឃ, បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន សូមព្រះភិក្ខុសង្ឃទទួលយកនូវវត្ថុទាំងឡាយ មានត្រៃបិដកជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់មាតាបិតាជាដើមផង ដល់ញាតិ និងមិត្រទាំងឡាយផង ដល់សព្វសត្វទាំងអស់ព្រមទាំងបរិវាររបស់ខ្លួនផង ដល់យើងខ្ញុំព្រះអង្គទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

។ល។ ជាគម្រប់ពីរដងផង ។

។ល។ ជាគម្រប់បីដងផង ។

## ៦.ពាក្យវេរសង្ឃភត្តថ្វាយសង្ឃ

**មយំ ភន្តេ ឥមានិ ខាទនីយភោជនីយាទីនិ សង្ឃេត្វា សង្ឃស្ស ទេម , សាធុ ភន្តេ សង្ឃោ ឥមានិ ខាទនីយភាជនីយាទីនិ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

**ទុតិយម្បិ ......។**

**តតិយម្បិ ..... ។**

បពិត្រព្រះគម្ពែងសង្ឃដដ៏ចម្រើន យើងខ្ញុំទាំងឡាយមាន គាក់តែង នូវវត្ថុទាំងឡាយ មានខាទនីយភាជនីយាហារ គឺបង្អែម និង ចម្អាបជាដើមនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ,បពិត្រព្រះគម្ពែង សង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយកនូវវត្ថុទាំងឡាយមានបង្អែម និងចម្អាបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាល ជាអង្វែងទៅហោង ។

..... អស់វារៈពីរដងផង ។

..... អស់វារៈបីដងផង ។



## ៧.ពាក្យវេរសង្ឃភត្តថ្វាយចំពោះសង្ឃ

**អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ (សង្ឃភត្តំ) សបរិក្ខារំ ពុទ្ធប្ប- មុខស្ស សង្ឃស្ស ទេម, តេ គុណវន្តាទយោ ឥមំ (សង្ឃភត្តំ) អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន ។**

**ទុតិយម្បិ ......។**

**តតិយម្បិ ......។**

បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន រីចង្ហាន់បិណ្ឌបាត នៃខ្ញុំព្រះករុណាទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើម យើងខ្ញុំទាំងឡាយ សូមផ្សេរ (នូវសង្ឃភត្ត) នេះ ព្រមទាំងបរិក្ខារ ប្រគេនដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន សូមលោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមនោះ សម្គាល់ (នូវសង្ឃភត្ត) នេះ ថាដូចជារបស់នៃខ្លួន ហើយសូមអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឱ្យបានរួចរំដោះចាកទុក្ខទាំងពួង ឱ្យបានសម្រេចនូវសម្បត្តិទាំងឡាយ ៣ ប្រការ គឺសម្បត្តិមនុស្ស១ សម្បត្តិទេវតា១ សម្បត្តិព្រះនិព្វាន ១ ដោយសមគួរតាមសេចក្ដីប្រាថ្នា របស់អស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្ស ដែលហួរជូនទៅមិនដាច់នេះហោង ។

..... អស់វារៈពីរដងផង ។

..... អស់វារៈបីដងផង ។

# គរុភណ្ឌ ២៥ យ៉ាង មិនត្រូវលះមិនត្រូវចែក

| | |
|---|---|
| **១ - អារាមោ** | អារាម គឺសួនច្បារ |
| **២ - អារាមវត្ថុ** | ទីដីដាំសួនច្បារ |
| **៣ - វិហារោ** | វិហារ គឺលំនៅ |
| **៤ - វិហារវត្ថុ** | ទីសម្រាប់សង់លំនៅ |
| **៥ - មញ្ចោ** | គ្រែ |
| **៦ - បីឋំ** | តាំង ឬកៅអី |
| **៧ - ភិសី** | ពូក |
| **៨ - ពិម្ពោហនំ** | ខ្នើយ |
| **៩ - លោហកុម្ភី** | ឆ្នាំងដែលធ្វើពីលោហជាតិ |
| **១០ - លោហភាណកំ** | ខ្ទះលោហៈ |
| **១១ - លោហវារកោ** | ខ្ទមលោហៈ |
| **១២ - លោហកដាហំ** | ផើងលោហៈ |
| **១៣ - វាសី** | កាំបិត |
| **១៤ - ផារសុ** | ពូថៅ |
| **១៥ - កុឋារី** | ដឹងចាំង |

**១៦ - កុទ្ទាលោ** ចប

**១៧ - និខាទនំ** ពន្លាក

**១៨ - វល្លិ** វល្លិ

**១៩ - វេឡុ** ឫស្សី

**២០ - មុញ្ជំ** ស្មៅជំណោកទន្សាយ

**២១ - បព្វជំ** ស្មៅយ៉ាផ្លង

**២២ - តិណំ** ស្មៅធម្មតា

**២៣ - មត្តិកា** ដីស្អិត

**២៤ - ទារុភណ្ឌំ** គ្រឿងឈើ

**២៥ - មត្តិកាភណ្ឌំ** គ្រឿងធ្វើពីដី

**ឥមានិ ខោ ភិក្ខវេ បញ្ច អវិស្សជ្ជិយានិ ន វិស្សជ្ជេតព្វានិ សង្ឃេន វា គណេន វា បុគ្គលេន វា វិស្សជ្ជិតានិបិ អវិស្សជ្ជិតានិ ហោន្តិ យោ វិស្សជ្ជេយ្យ អាបត្តិថុល្លច្ចយស្ស** ម្នាលភិក្ខុទាំងឡាយ របស់ទាំង ៥ ពួកនេះឯង ជារបស់មិនគួរលះចេញ ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវលះចេញ សូម្បីលះចេញហើយ ក៏មិនឈ្មោះថាលះ ភិក្ខុណាលះចេញ ត្រូវអាបត្តិថុល្លច្ច័យ ។ (វិនយបិដក ភាគ ១៣ ទំព័រ ១៤០ )

គរុភណ្ឌទាំង ២៥ នេះមាន **អារាម** ជាដើម កាលទាយកផវថ្វាយសង្ឃហើយ ឬសង្ឃហ្លួងហែងរក្សា ភិក្ខុសាមណេរ មិនអាចដើម្បីចែកវត្ថុណាមួយ ឱ្យមកជារបស់ខ្លួន ឬចំណែកបុគ្គល ទោះចែកគ្នាហើយក៏ដោយក៏មិនឈ្មោះថាចែកដែរ ព្រោះវត្ថុទាំងនោះ កាលណាបើចែករមែងប្រព្រឹត្តទៅជាអាបត្តិថុល្លច្ច័យ ។ បើប្រើប្រាស់វត្ថុទាំងនោះ មានការខូចខាត ឬក៏បាត់ ត្រូវសងសង្ឃវិញ កាលមិនសងឈ្មោះថាជំពាក់សង្ឃ ។

ចំណែកវត្ថុក្រៅអំពី គរុភណ្ឌទាំង ២៥ មានចីវរ និងចង្ហាន់បិណ្ឌបាតជាដើម កាលទាយកផវថ្វាយសង្ឃ ភិក្ខុសាមណេរ អាចអបលោកន៍ ចែកគ្នាប្រើប្រាស់បាន ។

# វិធីអបលោកន៍

**គឺជាវិន័យកម្ម ធ្វើរបស់លហុភ័ណ្ឌដែលជារបស់សង្ឃ ឱ្យបុគ្គលមានភិក្ខុសាមណេរជាដើម ប្រើប្រាស់បាន មិនឱ្យមានទោស ។**

- **សង្ឃធ្វើអបលោកបិណ្ឌបាត**

**សង្ឃំ ភន្តេ បុច្ឆាមិ ឥទានិ បិណ្ឌបាតោ សបរិក្ខារោ សង្ឃស្ស ឧប្បន្នោ ឥមេ សព្វេ អាគតានំ ភិក្ខូនំ យថាសុខំ បរិភុញ្ជិតុំ រុច្ចតិ សង្ឃស្ស**

**ទុតិយម្បិ** ...... ។

**តតិយម្បិ** ...... ។

បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំសូមសួរសង្ឃថា ឥឡូវនេះ បិណ្ឌបាតព្រមទាំងគ្រឿងបរិក្ខាកើតឡើងដល់សង្ឃ កាលដែលភិក្ខុទាំងឡាយ ដែលមកហើយបរិភោគវត្ថុទាំងពួងនេះ តាមសប្បាយ គាប់ចិត្តដល់សង្ឃឬ ?

ខ្ញុំសូមសួរសង្ឃជាគំរប់ ២ ដងផង ។ ល ។

ខ្ញុំសូមសួរសង្ឃជាគំរប់ ៣ ដងផង ។ ល ។

- **ការចែកមួយបែបទៀត**

ភិក្ខុខ្ចីពោលថា **ឥទំ មហាថេរស្ស បាបុណាតិ, អវសេសំ អម្ហាកំ បាបុ - ណន្តិ** នេះដល់ព្រះថេរៈ, វត្ថុដែលសេសសល់រមែងដល់ពួកយើង ។

ភិក្ខុចាស់ពោលថា **អយំ មយ្ហំ បាបុណាតិ, អវសេសំ តុម្ហាកំ បាបុណាតិ** នេះដល់ យើង, ដែលនៅសល់ ដល់ពួកលោក ។

<u>ម្យ៉ាងទៀត</u> **អយំ បឋមភាគោ មយ្ហំ បាបុណាតិ, អយំ ទុតិយភាគោ តុម្ហំ បាបុណាតិ** នេះចំណែកទី ១ រមែងដល់យើង, ចំណែកទី ២ នេះ រមែងដល់លោក ។

**<u>ភិក្ខុ ១ រូបធ្វើអធិដ្ឋាន ថា</u> មយ្ហំ ឥមេ បិណ្ឌបាតា សបរិក្ខារា បាបុណន្តិ** បិណ្ឌបាត ព្រមទាំងបរិក្ខាទាំងឡាយនេះ សម្រេចដល់អាត្មាអញ ។

<u>ឬតាំងទុកក្នុងចិត្តថា</u> **អញ្ញោ កោចិ ឥធ នត្ថិ មយ្ហំ ឯតា បាបុណន្តិ** ទីនេះមិនមាអ្នកណាៗ ដទៃ, បិណ្ឌបាតទាំងឡាយនេះ សម្រេចដល់អាត្មាអញ

**ព្រះពុទ្ធដីកា**

**ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានដោយសេចក្ដីជ្រះថ្លា ជឿកម្មផលដោយផលនៃទាននោះ កើតក្នុងទីណាៗ រមែងជាបុគ្គលស្ដុកស្ដម្ភ ជាអ្នកមានទ្រព្យច្រើន មានភោគៈច្រើន ជាបុគ្គលមានរូបល្អគួររមិលមើល ជាទីជ្រះថ្លា នាពជាអ្នកមានសម្បុរល្អដ៏ក្រៃលែង ។**

# ការបវារណា (និមន្តឱ្យប្រើប្រាស់)

ការបវារណាដោយអកប្បិយៈវត្ថុ (បានដល់មាសនិងប្រាក់ ឬលុយ) នេះគឺជាចំណុចសំខាន់ដែលពុទ្ធបរិស័ទត្រូវដឹង ព្រោះថាបើទាយកបវារណាខុស ហើយភិក្ខុត្រេកអរទទួល គឺ មិនបានហាមឃាត់ដោយកាយ វាចា ឬចិត្តទេ ទោះបីមិនបានកាន់នូវមាសនិងប្រាក់ដោយដៃរបស់ខ្លួនផ្ទាល់ មាសនិងប្រាក់ឬលុយ នោះ ជានិស្សគ្គិយ (១)ហើយភិក្ខុត្រូវអាបត្តិបាចិត្តិយៈ ដែរ ។

នៅក្នុងរូបិយសិក្ខាបទ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់បានបញ្ញត្តិយ៉ាងនេះថា : “ភិក្ខុណាមួយ កាន់យកនូវមាសនិងប្រាក់ដោយខ្លួនឯង ឬ ប្រើអ្នកដទៃឱ្យទទួលកាន់យក ឬមួយត្រេកអរចំពោះមាសនិងប្រាក់ ដែលគេទុកដាក់ឱ្យ មាសប្រាក់នោះជានិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយៈ” ។

នៅក្នុងបទបញ្ញត្តិថា “កាន់យកនូវមាស និងប្រាក់ដោយខ្លួនឯង ឬប្រើគេឱ្យទទួលកាន់យក” នេះ បានដល់ មាសប្រាក់ដែលគេ

(១) អាបត្តិណាញ៉ាំងកុសលចិត្តរមែងឱ្យធ្លាក់ចុះ ឈ្មោះថា បាចិត្តិយៈ ។
ទិ កុសលចិត្តំ បាតេតីតិ .បាចិត្តិយំ ។

បវារណាត្រឹមត្រូវក្តី មិនត្រឹមត្រូវក្តី ហើយភិក្ខុកាន់ គឺទុកដាក់ដោយខ្លួនឯង ឬប្រើអ្នកដទៃដែលមិនមែនជាកប្បិយការកៈទុកដាក់ឱ្យភិក្ខុនោះ ។

ក្នុងពាក្យថា “ ឬមួយត្រេកអរចំពោះមាស និងប្រាក់ដែលគេទុក ដាក់ឱ្យ ” នេះ បានដល់ ការត្រេកអរនូវអកប្បិយវត្ថុដែលគេបវារណាមិនបានត្រឹមត្រូវនុ៎ះឯង ។ តែបើភិក្ខុកំណត់បាននូវពាក្យដែលគេបវារណាខុសនោះហើយ ហាមឃាត់ដោយកាយជាដើម មិនជាអាបត្តិទេ ។

# របៀបបវារណាបច្ច័យ ៤

ឧបាសក ឧបាសិកា ដែលមានសេចក្តីជ្រះថ្លា ចង់ទុកដាក់ប្រាក់ ដើម្បីសម្រេចជាបច្ច័យ៤ដល់លោក គប្បីចូលទៅរកភិក្ខុសង្ឃដែលជាបដិគ្គាហកៈនោះ ហើយថ្វាយបង្គំ ៣ ដង បន្ទាប់មកពោលពាក្យបវារណា ទាំង ៣ បែបណាមួយ ដូចតទៅនេះ ដែលអដ្ឋកថាព្រះវិន័យបានសម្តែងទុក ។

# ពាក្យបវារណាអកប្បិយវត្ថុ

**១/ ឥទំ កប្បិយការកានំ ហត្ថេ ភវិស្សតិ តេវលំ តុម្ហេ ចត្តារោ បច្ចយេ បរិភុញ្ជថ ។** (បពិត្រលោកម្ចាស់ដ៏ចម្រើន រូបិយៈមានចំនួន............) នេះ នឹងមាននៅក្នុងដៃរបស់កប្បិយការកៈ សូមលោកម្ចាស់ប្រើប្រាស់នូវបច្ច័យបួនតែម្យ៉ាងចុះ ។

**២/ មយ្ហំ ហត្ថេ ភវិស្សតិ តេវលំ តុម្ហេ ចត្តារោ បច្ចយេ បរិភុញ្ជថ ។** (បពិត្រលោកម្ចាស់ដ៏ចម្រើន រូបិយៈមានចំនួន .... នេះ) នឹងមានក្នុងដៃ របស់ខ្ញុំព្រះករុណា សូមលោកម្ចាស់ ប្រើប្រាស់នូវ-បច្ច័យបួនតែម្យ៉ាង ។

**៣/ មម បុរិសានំ ហត្ថេ ភវិស្សតិ តេវលំ តុម្ហេ បច្ចយេ បរិភុញ្ជថ ។** (បពិត្រលោកម្ចាស់ដ៏ចម្រើន រូបិយៈមានចំនួន.....នេះ) នឹងមានក្នុងដៃនៃបុរសទាំងឡាយរបស់ខ្ញុំ សូមលោកម្ចាស់ ប្រើប្រាស់នូវបច្ច័យតែម្យ៉ាង ។

បន្ទាប់អំពីបានបវារណាត្រឹមត្រូវហើយ ប្រគល់ឱ្យកប្បិយការកៈ ឬវេយ្យាវច្ចៈរបស់លោកចុះ, កាលណាលោកមានសេចក្តីត្រូវដោយ-

បច្ច័យ៤ណាមួយ មានចីវរជាដើម លោកគ្រាន់តែប្រាប់ដល់វេយ្យាវច្ចៈ វេយ្យាវច្ចៈនោះនឹងរកនូវចីវរជាដើមនោះ ដោយរូបិយៈវត្ថុមកប្រគេនដល់ លោកជាមិនខាន ។

✤✤✤✤✤✤✤✤✤✤✤✤✤

**បុត្តា មត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ**
**អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តោ កុតោ ធនំ ។**

*ជនពាលតែងព្រួយលំបាក ដោយសេចក្ដីសម្គាល់ កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិតសូម្បីខ្លួនរបស់ខ្លួនក៏មិនមានផង ចំណង់បើកូនទាំងឡាយ នឹងរាប់ថាមានអំពីណាបាន ទ្រព្យនឹងរាប់ថា មានអំពីណាបាន ។*

# ការនិមន្តព្រះសង្ឃគង់ចាំវស្សា

ឧបាសក ឧបាសិកា ដែលមានសេចក្ដីជ្រះថ្លា ប្រាថ្នានិមន្តព្រះសង្ឃ ដើម្បីគង់ចាំវស្សាក្នុងវត្ត ឬក្នុងទីណាមួយ គប្បីចូលទៅរកព្រះសង្ឃ ហើយថ្វាយបង្គំ៣ដង រួចហើយពោលពាក្យអារាធនាព្រះសង្ឃឱ្យគង់ចាំវស្សា ដូចតទៅនេះ ។

**ភន្តេ, ឥមំ តេមាសំ ឥធេវ វសថ, មយំ ធម្មស្សវនញ្ច លភិត្វា, សទ្ធាយ ទានំ ទត្វា តីណិ សរណានិ គហេត្វា បញ្ចសុ សីលេសុ រក្ខិត្វា យថក្កមំ ឧបោសថកម្មានិ ករិស្សាម, ឯតំ ទីឃរត្តំ អត្ថាយ សុខាយ ហិតាយ ។**

បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយ គង់នៅក្នុងទីនេះឯង អស់បីខែនេះ, ខ្ញុំព្រះករុណាទាំងឡាយ នឹងបានស្ដាប់ព្រះធម៌ផង បានថ្វាយទានតាមសទ្ធាផង បានដល់នូវព្រះត្រៃសរណៈផង បានរក្សានូវសីលទាំងឡាយផង ហើយនឹងធ្វើនូវឧបោសថកម្មតាមសមគួរ ។ វិការគង់នៅរបស់លោកម្ចាស់ទាំងឡាយនេះ នឹងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដើម្បីសេចក្ដីចម្រើន អស់កាលជាអង្វែងតទៅ ។

# អនុមោទនារក្ខាយាចនគាថា

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ នោ[១] អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ ។**

ប្រែថា: ទេវតាទាំងឡាយ ដែលឋិតឮដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវព្រះពុទ្ធសាសនាឱ្យឋិតថេរ និងឱ្យរុង់រឿងយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ នោអនុមោទន្តុ ចិរំ រក្ខន្តុ រាជានោ ។**

ប្រែថា: ទេវតាទាំងឡាយដែលឋិតឮដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវព្រះរាជាទាំងឡាយឱ្យឋិតក្នុងរាជ្យ និងឱ្យមានជ័យជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**

---

[១]-**បុញ្ញំ នោ** បើសូត្រម្នាក់ឯងត្រូវថា **បុញ្ញំ មេ** ប្រែថា បុណ្យរបស់ខ្ញុំ។

**បុញ្ញំ នោអនុមោទន្តុ ចិរំ រក្ខន្តុ ញាតយោ ។**

ប្រែថាៈ ទេវតាទាំងឡាយដែលឋិតឰដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវពួកញាតិទាំងឡាយ (ឱ្យចម្រុងចម្រើន និងឱ្យសុខសាន្ត)ជាអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ ។**

ប្រែថាៈ ទេវតាទាំងឡាយ ដែលឋិតឰដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវសត្វទាំងឡាយឱ្យចម្រុងចម្រើន និងឱ្យសុខសាន្តជាអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ នោសទា ។**

ប្រែថាៈ ទេវតាទាំងឡាយ ដែលឋិតឰដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនា

នូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវយើងទាំងឡាយ (ឱ្យចម្រុងចម្រើន និងឱ្យសុខសាន្ត) យូរយារគ្រប់កាលទាំងពួង។

# តេជះខ្ញុំសាង

តេជះខ្ញុំសាង សំអិតសំអាង ឱនកាយវាចា
សូមសុខសុភាព រួចពីទុក្ខា ឆ្លងដល់ត្រើយមហា
ពោលគឺនិព្វាន ។

គ្រប់ជាន់គ្រប់ជាតិ កុំឱ្យខ្ញុំឃ្លាត ពីសីលនិងទាន
គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន
ដល់ស្ថានថ្លៃថ្លា។

ខ្ញុំជូនមគ្គផល ចំពោះទៅដល់ មាតាបិតា
គុណគ្រូឧបជ្ឈាយាចារ្យ គុណញាតិកា ប្រាំពីរសន្តាន។
ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកឋាន
ខ្ញុំជូនមគ្គផល កុសលច្រើនថ្កាន សូមសុខក្សេមក្សាន្ត
ដល់ស្ថានផុតទុក្ខ។

# ពាក្យឧទ្ទិទានសង្ខេប

ឥទំ ជោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ ។

វិទាននេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ បានដល់នូវសេចក្តីសុខចុះ ។

(បិដកលេខ ៥២ ទំព័រ ១៣ និងលេខ ៥៦ ទំព័រ ៤, ៧១)

# ពាក្យឧទ្ទិទានមួយបែបទៀត

**ឥទំ មេ ទានំ ញាតីនំ ហោតុ** ទានរបស់ខ្ញុំនេះ ចូលមានដល់ញាតិទាំងឡាយ

**ឥទំ មេ បុញ្ញំ អាសវក្ខយាវហំ ហោតុ** បុណ្យរបស់ខ្ញុំនេះ សូមជាបច្ច័យនាំមកនូវធម៌ជាទីអស់ទៅនៃ អាសវក្កិលេស

**ឥទំ មេ បុញ្ញំ និព្វានស្ស បច្ចយោ ហោតុ** បុណ្យរបស់ខ្ញុំនេះ ចូរជាបច្ច័យដល់នូវព្រះនិព្វាន

**មម បុញ្ញភាគំ សព្វសត្តានំ ភាជេមិ** ខ្ញុំសូមចែកចំណែកបុណ្យរបស់ខ្ញុំ ដល់សព្វសត្វទាំងឡាយ

**តេ សព្វេ មេ សមំ បុញ្ញភាគំ លភន្តុ** សូមសព្វសត្វទាំងអស់នោះ បានចំណែកបុណ្យ ស្មើនឹងខ្ញុំផងចុះ ។

**សាធុ! សាធុ! សាធុ!**

# សព្វទិសាសុមេត្តាផរណំ

(ការផ្សាយមេត្តាចិត្តដល់សព្វសត្វគ្រប់ទិស)

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ ឧបរិមាយ[១] ទិសាយ សត្តា អវេរា សុខី ហោន្តុ

សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ ។

---

១-ក្នុងសៀវភៅខ្លះ រៀបរៀងដាក់ **ឧបរិមាយ** មុន **ហេដ្ឋិមាយ** ។

**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា**
**សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។**

(បិដកលេខ ៧១ ទំព័រ ៩៨)

(ពាក្យដើមមានក្នុង ហើយបុរាណលោកនិពន្ធបន្ថែមផង)

ប្រែថាៈ **សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សូមពួកសត្វទាំងអស់ក្នុងទិសខាងកើត មិនមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សូមពួកសត្វទាំងអស់ក្នុងទិសអាគ្នេយ៍ មិនមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សូមពួកសត្វទាំងអស់ក្នុងទិសខាងត្បូង មិនមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សូមពួកសត្វទាំងអស់ក្នុងទិសនិរតី មិនមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សូមពួកសត្វទាំងអស់ក្នុងទិសខាងលិច មិនមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សូមពួកសត្វទាំងអស់ក្នុងទិសពាយ័ព្យ មិនមានពៀរនឹងគ្នា មានតែសេចក្ដីសុខ

**សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សូមពួកសត្វទាំងអស់ក្នុងទិសខាងជើង មិនមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សូមពួកសត្វទាំងអស់ក្នុងទិសឦសាន មិនមានពៀរនឹងគ្នា មានតែសេចក្ដីសុខ

**សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សូមពួកសត្វទាំងអស់ក្នុងទិសខាងក្រោម មិនមានពៀរនឹងគ្នា មានតែសេចក្ដីសុខ

**សព្វេ ឧបរិមាយ**[១] **ទិសាយ សត្តា អវេរា សុខី ហោន្តុ** សូមពួកសត្វទាំងអស់ក្នុងទិសខាងលើ មិនមានពៀរនឹងគ្នាមានតែសេចក្ដីសុខ។

**សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ** សូមពួកសត្វទាំងអស់កុំមានពៀរនឹងគ្នា សូមឱ្យបានសុខសូមឱ្យប្រាសចាកទុក្ខ

**អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ** សូមកុំឱ្យព្យាបាទគ្នា សូមកុំឱ្យមានសេចក្ដីចង្អៀនចង្អល់ចិត្ត សូមឱ្យមានអាយុវែង សូមកុំឱ្យ

---

១-ក្នុងសៀវភៅខ្លះ រៀបរៀងដាក់ **ឧបរិមាយ**“ ទិសខាងលើ ”មុន **ហេដ្ឋិមាយ**“ ទិសខាងក្រោម” ។

មានផាគ សូមឱ្យសម្រេងដោយសម្បត្តិទាំងឡាយ សូមរក្សានូវខ្លួនឱ្យនៅជាសុខ (តទៅ ) ។

**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា**

**សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។**

សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្ដីទុក្ខ សូមឱ្យជាសត្វបាត់សេចក្ដីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្ដីសោក សូមឱ្យជាសត្វបាត់សេចក្ដីសោកទៅ ។ ( បិដក ៧១ ទំព័រ ៩៨ )

# ផ្សាយមេត្តាចិត្តដល់សព្វសត្វសង្ខេប

**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា**

**សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។**

សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្ដីទុក្ខ សូមឱ្យជាសត្វបាត់សេចក្ដីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្ដីសោក សូមឱ្យជាសត្វបាត់សេចក្ដីសោកទៅ ។

# មួយបែបទៀតថា

**ឥទំ វត នោ បុញ្ញំ អាសវក្ខយាវហំ ហោតុ អនាគតេ កាលេ ។**

វីបុណ្យនៃយើងទាំងឡាយនេះ សូមឱ្យបានជាបច្ច័យ នាំមកនូវធម៌ជាទីអស់ទៅនៃអាសវក្កិលេស គឺព្រះនិព្វាន ឰដ៏អនាគតកាលទៅខាងមុខនោះហោង ។

**ឥទំ នោ ធម្មទានំ និព្វានបច្ចយោ ហោតុ អនាគតេ កាលេ**

វីធម្មទាននៃយើងទាំងឡាយនេះ ចូរជាបច្ច័យនៃព្រះនិព្វាន ក្នុងកាលជាអនាគត ។

# ពាក្យអធិដ្ឋានទាន

**សុទិន្នំ វត នោ ទានំ សព្វសម្បត្តិសិទ្ធកំ និព្វានសន្ទាតំ អាសវក្ខយាវហំ ហោតុ អនាគតេ កាលេ ៗ**

វីទាននៃយើងទាំងឡាយនេះ ដែលបានបូជាហើយដោយប្រពៃ សូមឱ្យ បានសម្រេចនូវសម្បត្តិទាំងពួង ទាំងសូមឱ្យបានជាបច្ច័យនាំមកនូវធម៌ ជាទីអស់ ទៅនៃអាសវក្កិលេស គឺព្រះនិព្វាន ឰដ៏អនាគតកាលទៅខាងមុខនោះហោង ។

# ពាក្យអធិដ្ឋាន

សូមឱ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឱ្យព្រះពុទ្ធសាសនាផ្សាយទូទៅ ពេញសកលលោក សូមឱ្យលោកទាំងមូលបានប្រកបដោយ សន្តិភាព ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា “**នត្ថិ សន្តិ បរំ សុខំ** ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ ” ។

**សព្វទានំ ធម្មទានំ ជិនាតិ សព្វរសំ ធម្មរសោ ជិនាតិ**

**សព្វរតី ធម្មរតិ ជិនាតិ តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។**

ធម្មទានឈ្នះអាមិសទានទាំងពួង ធម្មរសឈ្នះរសទាំងពួង សេចក្តីត្រេកអរក្នុងធម៌ឈ្នះសេចក្តីត្រេកអរទាំងពួង ការអស់តណ្ហាឈ្នះទុក្ខទាំងពួង ។ (ធម្មបទគាថា តណ្ហាវគ្គទី២៤ បិដក៥២ទំព័រ៩៦)

**ធម្មបូជា មហាបញ្ញោ** បូជាព្រះធម៌មានបញ្ញាច្រើន

*បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយក្នុងលោកទាំងពីរ*
*គឺរីករាយក្នុងលោកនេះផង ក្នុងលោកខាងមុខផង*
*បុគ្គលនោះរមែងរីករាយស្រស់ស្រាយ*
*ព្រោះបានឃើញអំពើល្អ*
*បរិសុទ្ធរបស់ខ្លួន ។*

វត្តអំពាយស្វាយ

# ឧបករណ៍ជំនួយក្នុងការរៀបរៀង

- **ព្រះត្រៃបិដក**
- **អដ្ឋកថាព្រះវិន័យ**
- **វិមតិវិនោទនីដីកា**
- **វិន័យខន្ធកៈ និង បរិវារៈ**
- **គ្រហស្ថជាសាវ័កល្អ** របស់ព្រះភិក្ខុសុវណ្ណជោតោ ភួងសុវណ្ណ
- **ប្រជុំភាណវារៈ បាលី-ប្រែ របស់បណ្ឌិត** សែម-សូរ
- **ប្រជុំភាណវារៈបាលី-ប្រែនិងសេចក្តីពន្យល់** របស់ភិក្ខុ រតនបញ្ញោ បុត្ត សំអឿន
- **វចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជ** ជួនណាត **(ជោតញ្ញាណោ)**

✍ 🕮 ✍

បេមតោ ជាយតេ សោកោ
បេមតោ ជាយតេ ភយំ
បេមតោ វិប្បមុត្តស្ស
នត្ថិ សោកោ កុតោ ភយំ ។

សេចក្តីសោកសៅ កើតមកអំពីសេចក្តីស្រឡាញ់ ភ័យកើតមកអំពីសេចក្តីស្រឡាញ់ សេចក្តីសោកសៅ រមែងមិនមានដល់បុគ្គលដែលរួចផុតហើយអំពីសេចក្តីស្រឡាញ់ ភ័យនឹងមានមកអំពីណាបាន ។